# អង្គការសហប្រជាជាតិ
# សេចក្តីពន្យល់ទូទៅលេខ១ ស្តីពី
# ការទទួលស្គាល់ដោយស្មើភាពគ្នានៅចំពោះមុខច្បាប់

អនុម័តដោយគណៈកម្មាធិការសិទ្ធិជនពិការ ក្នុងសម័យប្រជុំលើកទី១១

ថ្ងៃទី៣១ មីនា-១១ មេសា ឆ្នាំ២០១៤



អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

ចែកជូនដោយឥតគិតថ្លៃ

# អង្គការសហប្រជាជាតិ

# មតិយោបល់ទូទៅលេខ១

# ស្តីពី

# ការទទួលស្គាល់ដោយស្មើភាពគ្នានៅចំពោះមុខច្បាប់

អនុម័តដោយគណៈកម្មាធិការសិទ្ធិជនពិការ

ក្នុងសម័យប្រជុំលើកទី១១

ថ្ងៃទី៣១ ខែមីនា ដល់ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤


អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
*កម្ពុជា*

ខែមករា ឆ្នាំ២០១៨

# មាតិការឿង

កថាមុខ ........................................................................១

ខ្លឹមសារនៃមាត្រា១២ .........................................................៨

I. សេចក្តីផ្តើម .............................................................១១

II.ខ្លឹមសារគតិយុត្តិនៃមាត្រា១២ .......................................១៧

III. កាតព្វកិច្ចរបស់រដ្ឋភាគី ..............................................២៧

IV. ទំនាក់ទំនងជាមួយបទប្បញ្ញត្តិផ្សេងទៀត
នៃអនុសញ្ញា ............................................................៣៤

V. ការអនុវត្តនៅថ្នាក់ជាតិ ..............................................៤៩

# អនុសញ្ញាស្តីពីសិទ្ធិជនពិការ
# សេចក្តីពន្យល់ទូទៅលេខ១
# មាត្រា១២៖ ការទទួលស្គាល់ពីភាពស្មើគ្នាចំពោះមុខច្បាប់

## ការថាមុខ

អនុសញ្ញាស្តីពីសិទ្ធិជនពិការ តម្កល់ក្នុងច្បាប់អន្តរជាតិនូវគោលការណ៍ជាសកលនៃសមភាព សេចក្តីថ្លៃថ្នូរ ឯករាជ្យភាព ការចូលរួមពេញលេញក្នុងសង្គម និងការមិនរើសអើង នៅពេលដែលគោលការណ៍ទាំងនេះ ត្រូវយកមកអនុវត្តចំពោះជនពិការ។ អនុសញ្ញាស្តីពីសិទ្ធិជនពិការរៀបរាប់ពីសិទ្ធិដែលជនពិការទទួលបាន និងពីករណីយកិច្ចប្រទាក់ក្រឡាគ្នារបស់រដ្ឋភាគី ដើម្បីគោរព ការពារ និងអនុវត្តសិទ្ធិទាំងនេះ។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ នៅថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១២។

មាត្រា១២ នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ ធានាថាជនពិការត្រូវមានសិទ្ធិទទួលបាន ការទទួលស្គាល់ស្មើភាពគ្នានៅចំពោះមុខច្បាប់។ មាត្រានេះគូសបញ្ជាក់ឡើងវិញដល់ជនពិការនូវសិទ្ធិមនុស្សជាមូលដ្ឋាននេះ ដូចមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងក្នុងមាត្រា១៦នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជា ជារដ្ឋភាគី។

នៅឯសម័យប្រជុំលើកទី១១ ក្នុងខែមេសា ឆ្នាំ២០១៤ គណៈកម្មាធិការសិទ្ធិជនពិការរបស់អង្គការសហប្រជាជាតិ (គណៈកម្មាធិការ) បាន អនុម័តសេចក្តីពន្យល់ទូទៅមួយដើម្បីស្រាយបំភ្លឺពីវិសាលភាព និងអត្ថន័យ នៃមាត្រា៩។ គណៈកម្មាធិការដែលមានសមាជិកជាអ្នកជំនាញឯករាជ្យ ១៨រូប បោះឆ្នោតជ្រើសរើសដោយរដ្ឋភាគីនៃអនុសញ្ញា ត្រូវបានបង្កើតឡើងក្រោមមាត្រា៣៤នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការដើម្បីតាមឃ្លាំមើលពីការអនុវត្តអនុសញ្ញាដោយរដ្ឋភាគីទាំងអស់។ គណៈកម្មាធិការពិនិត្យរបាយការណ៍ដែលរដ្ឋភាគីតម្រូវឲ្យដាក់ជូនខ្លួនតាមកាលកំណត់។ រួចមក គណៈកម្មាធិការ អនុម័តសេចក្តីសង្កេតសន្និដ្ឋានសំរាប់រដ្ឋភាគីនីមួយៗ ដែលរួមបញ្ចូលទាំងអនុសាសន៍នានា ដែលត្រូវកែលម្អឲ្យស្របតាមកតិកាសញ្ញានេះ។

សម្រាប់ការកែលម្អបែបនេះឲ្យចេញជារូបរាងឡើង រដ្ឋភាគីត្រូវយល់ដោយសមហេតុផលអំពីប្រភេទ និងវិសាលភាពនៃកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញានេះ។ ការបរិយាយពីសេចក្តីពន្យល់ទូទៅនេះ គឺជាវិធីមួយដែលគណៈកម្មាធិការផ្តល់ជំនួយសំដៅដល់គោលបំណងនេះ។ តាមរយៈសេចក្តីពន្យល់ទូទៅរបស់ខ្លួន លើមាត្រានីមួយៗនៃអនុសញ្ញានេះ គណៈកម្មាធិការពន្យល់យ៉ាងលម្អិតពីវិធានការជាក់លាក់ ដោយបានរំពឹងថារដ្ឋភាគីនឹងបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមមាត្រានេះ។ សេចក្តីពន្យល់ទូទៅនានាពឹងផ្អែកទាំងស្រុងលើបទពិសោធន៍របស់គណៈកម្មាធិការ ក្នុងការពិនិត្យមើលពីស្ថានភាពនៃការអនុវត្តន៍សន្ធិសញ្ញានៅក្នុងបណ្តាប្រទេសនានានៅលើពិភពលោក ក៏ដូចជាអំពីការអនុវត្តល្អៗជាអន្តរជាតិ។ ការ

ស្វែងរកពត៌មានយ៉ាងសកម្មពីអ្នកពាក់ព័ន្ធទាំងអស់ ក្នុងដំណើរការនៃការចងក្រងសេចក្តីពន្យល់ទូទៅ គណៈកម្មាធិការបានទទួលផលច្រើនពីទស្សនវិស័យ និងបទពិសោធន៍ពីរដ្ឋនានា ពីអ្នកជំនាញសិទ្ធិពិការភាព ពីបណ្ឌិតសភានិងកន្លែងផ្សេងៗទៀត ព្រមទាំងពីអង្គការជនពិការទៀតផង។

គោលបំណងនៃសេចក្តីពន្យល់ទូទៅលេខ១ ស្តីពីមាត្រា១២ គឺចង់ផ្តល់ការណែនាំលំអិតបន្ថែមទៀត លើគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់សម្រាប់ជនពិការផ្នែករាងកាយ វិញ្ញាណ ចិត្តសាស្ត្រ ឬបញ្ញាស្មារតី ដើម្បីស្រាយបំភ្លឺពីកាតព្វកិច្ចរបស់រដ្ឋភាគីទាក់ទងទៅនឹងសិទ្ធិនេះ។

មាត្រា១២ បង្ហាញពីសិទ្ធិដែលមិនអាចបដិបញ្ញត្តិបានរបស់មនុស្សគ្រប់រូប ក្នុងការទទួលបានសមត្ថភាពផ្លូវច្បាប់ ដែលមានន័យថា មនុស្សគ្រប់រូបមានអំណាចក្នុងការអះអាងសិទ្ធិរបស់ខ្លួន ព្រមទាំងពង្រឹងឆន្ទៈនិងចំណង់ចំនូលចិត្តរបស់ខ្លួនក្រោមច្បាប់នេះ។មាត្រា១២ ផាត់ចោលគំរូនៃការធ្វើសេចក្តីសម្រេចជំនួស និងពេញចិត្តគំរូនៃការធ្វើសេចក្តីសម្រេចតាមបែបគាំពាររបស់ជនពិការ។ ការធ្វើសេចក្តីសម្រេចជំនួស គឺនៅពេលដែលសិទ្ធិរបស់មនុស្សម្នាក់ ក្នុងការសម្រេចអ្វីមួយដោយស្វ័យភាព និងចងកាតព្វកិច្ចតាមផ្លូវច្បាប់ ត្រូវបានដកហូតពីមនុស្សម្នាក់នោះ រួចហើយត្រូវបានផ្ទេរទៅឲ្យតតិយជនម្នាក់ទៀត។ ជាឧទាហរណ៍ កិច្ចការនេះ ត្រូវបានធ្វើឡើងជាទូទៅ តាមរយៈអាណាព្យាបាល អ្នកដែលតុលាការផ្តល់សិទ្ធិឲ្យ ឬច្បាប់ដែលអនុញ្ញាតិឲ្យមានការព្យាបាលដោយបង្ខំ ឬការឃុំឃាំងបុគ្គលដែលទំនងជាទទួលរងការអន់ថយខាងសមត្ថភាពផ្លូវចិត្ត។

ការផ្ទេរសមត្ថភាពផ្លូវច្បាប់ទៅតតិយជន គឺជាការបដិសេធមួយនៃសិទ្ធិទទួលបានការទទួលស្គាល់ពីភាពស្មើគ្នាចំពោះមុខច្បាប់របស់មនុស្ស។ ការធ្វើបែបនេះ គណៈកម្មាធិការយល់ឃើញថា ច្បាប់ទាំងអស់ដែលអនុញ្ញាតឲ្យមានការធ្វើសេចក្តីសម្រេចជំនួសត្រូវតែលុបបំបាត់ចោល។ ប្រការនេះ ត្រូវអនុវត្តដោយស្មើគ្នាចំពោះជនពិការផ្លូវចិត្ត និងបញ្ញា រួមទាំងជនពិការរូបរាងកាយផង។

គណៈកម្មាធិការចាត់ទុកថា ការធ្វើសេចក្តីសម្រេចដោយមានការគាំពារមានលក្ខណៈប្រសើរជាងដោយអនុញ្ញាតិឱ្យជនពិការប្រើប្រាស់សិទ្ធិទទួលបានការទទួលស្គាល់តាមផ្លូវច្បាប់របស់ពួកគេ ក្រោមអនុសញ្ញា។ ប្រសិនបើមនុស្សម្នាក់មានពិការភាពដែលប៉ះពាល់ដល់សមត្ថភាពនៃការធ្វើសេចក្តីសម្រេចរបស់ខ្លួន គាត់ត្រូវតែមានមធ្យោបាយមួយ ដើម្បីស្វែងរក និងទទួលបានការគាំពារដើម្បីអនុវត្តសមត្ថភាពខាងផ្លូវច្បាប់របស់ខ្លួន ដូចជាក្នុងករណីកម្មសិទ្ធិលើទ្រព្យសម្បត្តិ កិច្ចការហិរញ្ញវត្ថុ ការសម្រេចពីការថែទាំសុខភាព សេវាកិច្ចសន្យា...ក្នុងរាល់ការធ្វើសេចក្តីសម្រេច។

ប្រភេទ និងកម្រិតនៃការគាំពារ ដែលនឹងត្រូវផ្តល់ឱ្យជនពិការក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចរបស់ពួកគេ នឹងប្រែប្រួលស្របតាមភាពចម្រុះនៃតម្រូវការ។ បន្ថែមទៅលើការផ្តល់ការគាំពារ រដ្ឋត្រូវធានាឲ្យមានកិច្ចការពារគ្រប់គ្រាន់ ដើម្បីផ្តល់ការការពារពីការរំលោភបំពាន។ កិច្ចការពារទាំងនេះ គួរធានាថាការគាំពារណាមួយដែលផ្តល់ជូន គឺត្រូវបានធ្វើយ៉ាងប្រាកដ តាមវិធីមួយដែលសិទ្ធិ ឆន្ទៈ និងចំណង់ចំនួលចិត្តរបស់មនុស្សម្នាក់ត្រូវបានតំណាងយ៉ាងត្រឹមត្រូវ។

រដ្ឋមានកាតព្វកិច្ចគោរពសិទ្ធិជនពិការទទួលបានការទទួលស្គាល់ពីភាពស្មើគ្នាចំពោះមុខច្បាប់ ការពាររូបវន្តបុគ្គល និងបុគ្គលដែលមិនមែនជារដ្ឋ មិនឱ្យប៉ះពាល់សិទ្ធិជនពិការ និងផ្តល់មធ្យោបាយចាំបាច់ដល់ជនពិការក្នុងការអនុវត្តសិទ្ធិមានសមត្ថភាពផ្លូវច្បាប់របស់ខ្លួន។ រដ្ឋត្រូវលុបចោលនូវច្បាប់ដែលបដិសេធយ៉ាងជាក់ស្តែង ឬដឹមានប្រសិទ្ធភាពនូវសមត្ថភាពផ្លូវច្បាប់របស់ជនពិការ សូម្បីតែច្បាប់ទាំងនោះធ្វើតែម្តងចំពោះសេចក្តីសម្រេចតែមួយក៏ដោយ។ រដ្ឋត្រូវដាក់ជំនួសរបបនៃការធ្វើសេចក្តីសម្រេចជំនួស ដោយរបបជម្រើសផ្សេងៗតាមបែបគាំពារវិញ ដែលផ្តល់ជាបឋមដល់ឆន្ទៈ និងចំណង់ចំនូលចិត្តពិតប្រាកដរបស់មនុស្សម្នាក់ និងអាចធ្វើឱ្យបុគ្គលនោះទទួលបានពេញលេញនូវសិទ្ធិមនុស្សរបស់ខ្លួន។

សិទ្ធិទទួលបានការទទួលស្គាល់ពីភាពស្មើគ្នាចំពោះមុខច្បាប់ ដូចដែលបានការពារក្រោមមាត្រា១២ ត្រូវបានចងភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងសិទ្ធិដទៃទៀតនៃអនុសញ្ញា។ នៅក្នុងខ្លឹមសារគ្រឹះភាគច្រើន សមត្ថភាពផ្លូវច្បាប់មានសារៈសំខាន់ណាស់ ដើម្បីក្លាយជាអ្នកកាន់កាប់សិទ្ធិ និងដើម្បីមានជំហរពង្រឹងសិទ្ធិរបស់ខ្លួន។ ការគោរពសិទ្ធិមានសមត្ថភាពផ្លូវច្បាប់របស់ជនពិការជួយពន្លាតដល់ការការពារសេរីភាព សន្តិសុខ និងការយល់ព្រម ហើយហាមប្រាមដល់ការដកហូតសេរីភាពតាមទំនើងចិត្ត។ ការប្រព្រឹត្តដោយបង្ខំគឺជាការបំពានលើមាត្រា១២ ក៏ដូចជាការបំពានលើសិទ្ធិបូរណភាពបុគ្គល និងសេរីភាពរួចផុតពីទារុណកម្ម អំពើហិង្សា និងការបំពាន។ មនុស្សមានសិទ្ធិរស់នៅដោយឯករាជ្យក្នុងសហគមន៍។ ការរស់

នៅក្នុងសហគមន៍ផ្តល់នូវប្រព័ន្ធគាំពារមួយ តាមរយៈបណ្តាញសង្គម ហើយជាកត្តាដ៏សំខាន់មួយ នៃការធ្វើសេចក្តីសម្រេចតាមបែបគាំពារដែលរដ្ឋត្រូវបានអំពាវនាវរកឲ្យមានការគាំពារ។

ការទទួលស្គាល់ពីភាពស្មើគ្នាជាមនុស្សចំពោះមុខច្បាប់ គឺជាសិទ្ធិមួយដែលត្រូវបានធានាការពារដល់មនុស្សគ្រប់រូប ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ សិទ្ធិនេះត្រូវបានតាក់តែងឡើងនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ ក្នុងលក្ខខណ្ឌដែលសំដៅជាពិសេសដល់ស្ថានភាព ដែលជនពិការបានជួបប្រទះជាទូទៅ។ សេចក្តីពន្យល់ទូទៅនេះ សង្កត់ធ្ងន់ទៅលើគោលការណ៍ដែលវាមិនដែលអាចទទួលយកបាន ក្នុងការបដិសេធមនុស្សណាម្នាក់នូវបុគ្គលិកលក្ខណៈគតិយុត្តិរបស់គេ ឬក៏ដកហូតសមត្ថភាពផ្លូវច្បាប់របស់គេនោះឡើយ។ ផ្ទុយទៅវិញ រដ្ឋភាគីមានកាតព្វកិច្ចផ្តល់យន្តការគាំពារគ្រប់គ្រាន់ដើម្បីឱ្យជនពិការអាចបង្ហាញ និងអនុវត្តសិទ្ធិ ឆន្ទៈ និងចំណង់ចំនូលចិត្តរបស់ពួកគេបាន។

ក្នុងការតាក់តែងសេចក្តីពន្យល់ទូទៅលេខ១ គណៈកម្មាធិការបានបោះជំហានថ្មីមួយចំពោះបញ្ហានៃសមត្ថភាពផ្លូវច្បាប់របស់ជនពិការដែលអាចត្រូវបានរៀបរាប់ថាជាការវិវត្តន៍មួយ។ ការធ្វើសេចក្តីសម្រេចជំនួសបានក្លាយជាទម្លាប់ដ៏យូរមួយ ដែលសិទ្ធិរបស់ជនពិការត្រូវបានរំលោភបំពានដោយនិទណ្ឌភាព ដោយជារឿយៗ នៅពេលអ្នកដទៃផ្សេងទៀតបានជឿជាក់ថា ជនពិការត្រូវមានទីតាំងប្រសើរជាងនេះ ដើម្បីយល់ដឹង

ពីអ្វីដែលជាឧត្តមប្រយោជន៍របស់ជនពិការ ដែលខូចខាតការសំដែង ជាពិសេស នៅពេលធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងការផ្ទេរទ្រព្យ។ ជាមួយនឹងមាត្រា១២ នៃអនុសញ្ញា និងសេចក្តីពន្យល់ទូទៅនេះ បន្ទុកនៃការបង្ហាញភស្តុតាង មិនអាចដាក់លើជនពិការឲ្យបង្ហាញថា ពួកគេមានសមត្ថភាពក្នុងការធ្វើសេចក្តីសម្រេចផ្លូវច្បាប់ទៀតហើយ។ តាមសំណើររបស់ពួកគេ កាតព្វកិច្ចអនុវត្តឥឡូវនេះ គឺសំដៅទៅលើរដ្ឋដើម្បីផ្តល់ការគាំពារចាំបាច់ដល់ជនពិការ ដើម្បីឱ្យពួកគេអាចបង្ហាញពីឆន្ទៈរបស់ខ្លួនបាន។

ការបកប្រែទៅជាភាសាខ្មែរនេះ គឺជាការចូលរួមពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា សំដៅធ្វើឲ្យសិទ្ធិនេះ ក្លាយជាការពិត សម្រាប់ជនពិការកម្ពុជាទាំងអស់។

**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស**
**កម្ពុជា**
**ខែមករា ឆ្នាំ២០១៨**

## មាត្រា១២ : ការទទួលស្គាល់ពីភាពស្មើគ្នាចំពោះមុខច្បាប់

១- រដ្ឋភាគីអះអាងជាថ្មីថា ជនពិការមានសិទ្ធិត្រូវបានទទួលស្គាល់នៅគ្រប់ទីកន្លែងទាំងអស់ ថា ជាមនុស្សនៅចំពោះមុខច្បាប់។

២- រដ្ឋភាគីត្រូវទទួលស្គាល់ថាជនពិការមានសមត្ថភាព តាមផ្លូវច្បាប់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀតក្នុងគ្រប់ទិដ្ឋភាពនៃឆាកជីវិត។

៣- រដ្ឋភាគីត្រូវចាត់វិធានការសមស្របនានា ដើម្បីផ្តល់លទ្ធភាពឱ្យជនពិការទទួលបានការជួយឧបត្ថម្ភ ដែលពួកគេអាចត្រូវការក្នុងការអនុវត្តន៍សមត្ថភាពតាមផ្លូវច្បាប់របស់ពួកគេ។

៤- រដ្ឋភាគីត្រូវធានាថា រាល់វិធានការដែលពាក់ព័ន្ធនឹងការអនុវត្តន៍សមត្ថភាពតាមផ្លូវច្បាប់ ផ្តល់នូវការការពារយ៉ាងសមរម្យ និងមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការបំពាន អនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ការការពារបែបនេះ ត្រូវធានាថា វិធានការទាំងឡាយ ដែលទាក់ទងនឹងការអនុវត្តន៍សមត្ថភាពតាមផ្លូវច្បាប់ គោរពសិទ្ធិ ឆន្ទៈ និងចំណង់ចំណូលចិត្តរបស់ជនពិការ ត្រូវបានរួចផុតពីទំនាស់ផលប្រយោជន៍ និងឥទ្ធិពលមិនត្រឹមត្រូវ ត្រូវតែសមាមាត្រ និងបន្ថែមបន្ថយ ទៅតាមកាលៈទេសៈរបស់ជនពិការ អនុវត្ត

ក្នុងរយៈពេលខ្លីបំផុត តាមដែលអាចធ្វើទៅបាន និងត្រូវបានពិនិត្យឡើងវិញជាទៀងទាត់ ដោយអាជ្ញាធរមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀងមួយ ឬស្ថាប័នតុលាការ។ ការការពារទាំងនេះ ត្រូវតែសមាមាត្រទៅនឹងកម្រិតដែលវិធានការបែបនេះ មានផលប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ជនពិការ។

៥- អនុលោមតាមបទបញ្ញត្តិនៃមាត្រានេះ រដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្របនិងមានប្រសិទ្ធភាពដើម្បីធានាឱ្យជនពិការមានសិទ្ធិស្មើគ្នាក្នុងការធ្វើជាម្ចាស់លើទ្រព្យសម្បត្តិ ឬទទួលមរតកក្នុងការត្រួតពិនិត្យកិច្ចការហិរញ្ញវត្ថុផ្ទាល់ខ្លួនផ្សេងៗ និងមានសិទ្ធិស្មើគ្នាចំពោះការខ្ចីឥណទានធនាគារ ការបញ្ចាំ និងទម្រង់ផ្សេងៗទៀតនៃឥណទានហិរញ្ញវត្ថុហើយត្រូវធានាថាជនពិការមិនត្រូវបានគេដកហូតយកទ្រព្យសម្បត្តិរបស់ពួកគេតាមអំពើចិត្តនោះទេ។

# I. សេចក្តីផ្តើម

១. ភាពស្មើគ្នានៅចំពោះមុខច្បាប់ គឺជាគោលការណ៍ទូទៅជាមូលដ្ឋានមួយនៃការការពារសិទ្ធិមនុស្ស និងមិនអាចខ្វះបានសម្រាប់ការអនុវត្តសិទ្ធិមនុស្សផ្សេងទៀត។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយធានា ជាពិសេស ចំពោះសិទ្ធិក្នុងការទទួលបាននូវភាពស្មើគ្នានៅចំពោះមុខច្បាប់។ មាត្រា១២ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ រៀបរាប់បន្ថែមអំពីខ្លឹមសារមាត្រានៃសិទ្ធិពលរដ្ឋមួយនេះ និងផ្តោតទៅលើវិស័យទាំងឡាយណា ដែលជនពិការតែងតែត្រូវបានគេបដិសេធ មិនផ្តល់សិទ្ធិឲ្យជាប្រពៃណីទៅហើយនោះ។ មាត្រា១២ មិនបានចែងឲ្យមានសិទ្ធិបន្ថែមសម្រាប់ជនពិការនោះទេ គឺថាមាត្រានេះរៀបរាប់យ៉ាងសាមញ្ញអំពីធាតុទាំងឡាយ ដែលតម្រូវឲ្យរដ្ឋភាគីពិចារណា ដើម្បីធានាឲ្យមានសិទ្ធិស្មើភាពគ្នានៅចំពោះមុខច្បាប់ សម្រាប់ជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។

២. ដោយសារតែសារៈសំខាន់នៃមាត្រានេះ គណៈកម្មាធិការបានសម្រួលឲ្យមានវេទិកាបែបអន្តរកម្មមួយចំនួន សម្រាប់កិច្ចពិភាក្សាអំពីសមត្ថភាពខាងផ្នែកច្បាប់នេះ។ ចាប់តាំងពីការផ្លាស់ប្តូរយោបល់ដ៏មានប្រយោជន៍ខ្លាំងមួយ ស្តីពីបទប្បញ្ញត្តិនៃមាត្រា១២ ដែលធ្វើឡើងដោយអ្នកជំនាញ រដ្ឋភាគី អង្គការជនពិការ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នត្រួតពិនិត្យសន្ធិសញ្ញា ស្ថាប័នសិទ្ធិមនុស្សជាតិ និងទីភ្នាក់ងារអង្គការសហប្រជាជាតិនោះមក គណៈកម្មាធិការយល់ឃើញថាវាជាការចាំបាច់ត្រូវតែផ្តល់ការណែនាំបន្ថែមទៀតនៅក្នុងសេចក្តីពន្យល់ទូទៅមួយ។

៣. ផ្អែកទៅលើរបាយការណ៍បឋមជាច្រើនរបស់រដ្ឋផ្សេងៗគ្នា ដែលត្រូវបានធ្វើការត្រួតពិនិត្យរហូតមកទល់នឹងពេលនេះ គណៈកម្មាធិការសង្កេតឃើញថា មានការយល់ខុសជាទូទៅមួយអំពីវិសាលភាពពិតប្រាកដ នៃកាតព្វកិច្ចរបស់រដ្ឋភាគី ក្រោមមាត្រា១២ នៃអនុសញ្ញានេះ។ តាមពិតទៅ មានការខកខានមិនបានយល់ដឹងជាទូទៅមួយ ដែលថា វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សនៃពិការភាពតម្រូវឲ្យមានការផ្លាស់ប្តូរ ពីបទដ្ឋានធ្វើការសម្រេចចិត្តជំនួស ទៅជាបទដ្ឋានមួយដែលផ្អែកទៅលើការធ្វើការសម្រេចចិត្តដែលមានការគាំទ្រ។ គោលបំណងនៃសេចក្តីពន្យល់ទូទៅនេះ គឺដើម្បីស្វែងយល់បន្ថែម អំពីកាតព្វកិច្ចទូទៅ ដែលកើតចេញពីសមាសធាតុផ្សេងៗគ្នានៃមាត្រា១២។

៤. សេចក្តីពន្យល់ទូទៅនេះឆ្លុះបញ្ចាំងអំពីការបកស្រាយមាត្រា១២ ដែលផ្អែកលើគោលការណ៍ទូទៅជាច្រើន នៃអនុសញ្ញានេះ ដូចបានរៀបរាប់ក្នុងមាត្រា៣ ដូចជា ការគោរពសេចក្តីថ្លៃថ្នូរដែលមានពីកំណើត ស្វ័យភាពបុគ្គល រួមទាំងសេរីភាពរបស់បុគ្គលម្នាក់ៗ ក្នុងការជ្រើសរើសដោយខ្លួនឯងផ្ទាល់ និងឯករាជ្យភាពរបស់បុគ្គល ការមិនរើសអើង ការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាព និងការដាក់បញ្ចូលទៅក្នុងសង្គម ការគោរពជនពិការគ្រប់ប្រភេទ ហើយត្រូវទទួលស្គាល់ជនពិការជាចំណែកនៃភាពចម្រុះគ្នារបស់មនុស្ស និងមនុស្សជាតិ ឱកាសស្មើភាពគ្នា ការបង្កលក្ខណៈងាយស្រួលដល់ជនពិការ សមភាពរវាងបុរស និងស្ត្រី ព្រមទាំងការគោរពដល់សមត្ថភាពរីកចម្រើនរបស់កុមារពិការ និងការគោរពសិទ្ធិកុមារពិការ ដើម្បីរក្សានូវអត្តសញ្ញាណរបស់ពួកគេ។

៥. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ សុទ្ធតែមានបញ្ជាក់ច្បាស់ថា សិទ្ធិទទួលបានការទទួលស្គាល់ដោយស្មើភាពគ្នានៅចំពោះមុខច្បាប់ ត្រូវអនុវត្ត "គ្រប់កន្លែង"។ ឬម្យ៉ាងទៀតអាចនិយាយបានថា មិនមានកាលៈទេសៈណាក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលអនុញ្ញាតឲ្យដកហូតសិទ្ធិបុគ្គលក្នុងការទទួលបានការទទួលស្គាល់ក្នុងនាមជាបុគ្គលនៅចំពោះមុខច្បាប់ ឬដែលគេអាចដាក់កំហិតលើសិទ្ធិនេះបានឡើយ។ ចំណុចនេះត្រូវបានពង្រឹងបន្ថែមដោយមាត្រា៤ កថាខណ្ឌ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលចែងថា មិនមានការដកហូតណាមួយពីសិទ្ធិនេះត្រូវអនុញ្ញាតិឡើយ សូម្បីតែក្នុងពេលដែលមានភាពអាសន្នជាសាធារណៈក៏ដោយ។ ទោះបីជាមានការហាមប្រាមសមមូលណាមួយ ស្តីពីការដកហូតសិទ្ធិ ក្នុងការទទួលបានការទទួលស្គាល់ដោយស្មើភាពគ្នានៅចំពោះមុខច្បាប់មិនមានបញ្ជាក់ច្បាស់ នៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការនេះក៏ដោយ ក៏បទប្បញ្ញត្តិក្នុងកតិកាសញ្ញាអន្តរជាតិគ្របដណ្តប់ទៅលើការការពារបែបនេះដោយ ផ្អែកតាមមាត្រា៤ កថាខណ្ឌ៤ នៃអនុសញ្ញា ដែលចែងថា បទប្បញ្ញត្តិទាំងឡាយក្នុងអនុសញ្ញាស្តីពីសិទ្ធិជនពិការ មិនផ្ទុយនឹងច្បាប់អន្តរជាតិដែលមានស្រាប់នោះទេ។

៦. សិទ្ធិទទួលបានភាពស្មើគ្នានៅចំពោះមុខច្បាប់ ក៏ត្រូវបានឆ្លុះបញ្ចាំងក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សតំបន់ និងអន្តរជាតិសំខាន់ៗដទៃទៀតដែរ។ មាត្រា១៥ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើស

រើសអើងប្រឆាំងនារីភេទ ធានាឲ្យមានភាពស្មើគ្នារបស់ស្ត្រីនៅចំពោះមុខច្បាប់ និងតម្រូវឲ្យមានការទទួលស្គាល់សមត្ថភាពផ្លូវច្បាប់របស់ស្ត្រី ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយបុរស ដោយរាប់បញ្ចូលទាំងការធ្វើកិច្ចសន្យា ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការប្រើប្រាស់សិទ្ធិក្នុងប្រព័ន្ធយុត្តិធម៌។ មាត្រា៣ នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងពលរដ្ឋ ចែងអំពីសិទ្ធិរបស់បុគ្គលគ្រប់រូបថាមានភាពស្មើគ្នានៅចំពោះមុខច្បាប់ និងទទួលបាននូវការការពារ ដោយស្មើភាពគ្នាចំពោះមុខច្បាប់។ មាត្រា៣ នៃអនុសញ្ញាអាមេរិច ស្តីពីសិទ្ធិមនុស្ស មានចែងអំពីសិទ្ធិទទួលបានបុគ្គលិកលក្ខណៈផ្នែកតុលាការ និងសិទ្ធិរបស់បុគ្គលគ្រប់រូប ក្នុងការទទួលបានការទទួលស្គាល់ក្នុងនាមជាបុគ្គលនៅចំពោះមុខច្បាប់។

៧. រដ្ឋភាគី ត្រូវតែពិនិត្យឲ្យបានគ្រប់ជ្រុងជ្រោយទៅលើវិស័យទាំងអស់នៃច្បាប់ ដើម្បីធានាថា សិទ្ធិជនពិការក្នុងការទទួលបានសមត្ថកិច្ចខាងផ្នែកច្បាប់ មិនត្រូវទទួលរងការរិតត្បិត ដោយឈរលើមូលដ្ឋានមិនស្មើភាពគ្នាជាមួយបុគ្គលដទៃទៀតនោះទេ។ តាមប្រវត្តិសាស្ត្រ យើងឃើញថា ជនពិការត្រូវបានគេបដិសេធមិនឲ្យមានសិទ្ធិទទួលបានសមត្ថភាពខាងផ្នែកច្បាប់នៅក្នុងវិស័យជាច្រើន ក្នុងលក្ខណៈនៃការរើសអើងក្រោមរបបធ្វើការសម្រេចចិត្តជំនួស ដូចជា ភាពជាអាណាព្យាបាល ភាពជាអ្នកគ្រងថែរក្សា និងច្បាប់ស្តីពីសុខភាពផ្លូវចិត្ត ដែលអនុញ្ញាតឲ្យមានការព្យាបាលដោយបង្ខំ។ ការអនុវត្តទាំងនេះត្រូវតែលុបចោល ដើម្បីធានាថា សមត្ថភាពខាងផ្នែកច្បាប់ពេញលេញ ត្រូវបានធានាដល់ជនពិការដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។

៨. មាត្រា១២ នៃអនុសញ្ញានេះបញ្ជាក់យ៉ាងច្បាស់ថា ជនពិការគ្រប់រូបមានសមត្ថភាពខាងផ្នែកច្បាប់ពេញលេញ។ សមត្ថភាពខាងផ្នែកច្បាប់ ត្រូវបានគេបដិសេធដែលធ្វើឲ្យខូចប្រយោជន៍ ដល់ក្រុមជាច្រើនក្នុងប្រវត្តិសាស្ត្រកន្លងមក ដោយរាប់បញ្ចូលទាំងស្ត្រី (ជាពិសេស ក្រោយពេលរៀបអាពាហ៍ពិពាហ៍) និងនិគមជនភាគតិច។ ក៏ប៉ុន្តែ ជនពិការនៅតែជាក្រុម ដែលត្រូវគេបដិសេធសមត្ថភាពខាងផ្នែកច្បាប់ច្រើនជាងគេបំផុតក្នុងប្រព័ន្ធច្បាប់ជុំវិញពិភពលោក។ សិទ្ធិទទួលបានការទទួលស្គាល់ដោយស្មើភាពគ្នានៅចំពោះមុខច្បាប់ បញ្ជាក់ន័យថាសមត្ថភាពខាងផ្នែកច្បាប់ គឺជាលក្ខណៈសកលដែលមានជាប់ជាមួយមនុស្សទាំងអស់ដោយសារតែភាពជាមនុស្សជាតិ និងត្រូវតែលើកតម្កើងសម្រាប់ជនពិការដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។ សមត្ថភាពខាងផ្នែកច្បាប់ជាចំណុចមិនអាចខ្វះបាន សម្រាប់ការប្រើប្រាស់សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គមកិច្ច និងសិទ្ធិវប្បធម៌។ ចំណុចនេះទទួលបានភាពសំខាន់ ជាពិសេសសម្រាប់ជនពិការ នៅពេលដែលពួកគេត្រូវធ្វើការសម្រេចចិត្តជាមូលដ្ឋានពាក់ព័ន្ធនឹងសុខភាព ការអប់រំ និងការងាររបស់គេ។ (ក្នុងករណីជាច្រើន ការបដិសេធសមត្ថភាពខាងផ្នែកច្បាប់របស់ជនពិការបណ្តាលឲ្យមានការដកហូតសិទ្ធិមូលដ្ឋានជាច្រើនផ្សេងៗទៀត រួមមាន សិទ្ធិបោះឆ្នោត សិទ្ធិរៀបអាពាហ៍ពិពាហ៍ និងបង្កើតគ្រួសារ សិទ្ធិបន្តពូជ សិទ្ធិជាឪពុកម្តាយ សិទ្ធិផ្តល់ការយល់ព្រមសម្រាប់ទំនាក់ទំនងជិតស្និទ្ធ និងសម្រាប់ការព្យាបាលវេជ្ជសាស្ត្រ ព្រមទាំងសិទ្ធិទទួលបានសេរីភាព)។

៩. ជនពិការទាំងអស់ រួមទាំងអ្នកមានភាពអន់ខ្សោយផ្នែករាងកាយ ផ្លូវចិត្ត ផ្លូវបញ្ញា ឬផ្លូវវិញ្ញាណអាចទទួលរងផលប៉ះពាល់ដោយសារការបដិសេធសមត្ថភាពខាងផ្នែកច្បាប់និងការធ្វើសេចក្តីសម្រេចចិត្តជំនួស។ ទោះជាយ៉ាងណាក៏ដោយ ជនពិការគំនិត និងជនពិការចិត្តសង្គម នៅតែទទួលរងផលប៉ះពាល់ ដោយមិនសមាមាត្រតាមរយៈរបបធ្វើការសម្រេចចិត្តជំនួស និងការបដិសេធសមត្ថភាពខាងផ្នែកច្បាប់។ គណៈកម្មាធិការបានបញ្ជាក់ឡើងវិញថា ឋានៈរបស់បុគ្គលក្នុងនាមជាជនពិការ ឬអត្ថិភាពនៃភាពអន់ខ្សោយ (ដោយរាប់បញ្ចូលទាំងភាពអន់ខ្សោយខាងរាងកាយ ឬខាងវិញ្ញាណផងនោះ) មិនត្រូវបានគេប្រើជាមូលដ្ឋានសម្រាប់បដិសេធសមត្ថភាពខាងផ្នែកច្បាប់ ឬសិទ្ធិណាមួយដែលមានចែងក្នុងមាត្រា១២ នោះទេ។ ការអនុវត្តទាំងអស់ដែលមានបំណង ឬមានឥទ្ធិពលរំលោភទៅលើមាត្រា១២ ត្រូវតែលុបបំបាត់ចោល ក្នុងគោលបំណងដើម្បីធានាថា សមត្ថភាពខាងផ្នែកច្បាប់ពេញលេញ ត្រូវបានស្តារឡើងវិញដល់ជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។

១០. មតិយោបល់ទូទៅនេះ ផ្តោតជាចម្បងទៅលើខ្លឹមសារគតិយុត្តិនៃមាត្រា១២ និងទៅលើកាតព្វកិច្ចនានារបស់រដ្ឋដែលលេចឡើង។ គណៈកម្មាធិការនឹងបន្តធ្វើការក្នុងវិស័យនេះ និងផ្តល់នូវការពណ៌នាបន្ថែមកាន់តែស៊ីជម្រៅ អំពីសិទ្ធិ និងកាតព្វកិច្ចក្នុងមាត្រា១២ រួមជាមួយនឹងសេចក្តីសង្កេតសន្និដ្ឋាន មតិយោបល់ទូទៅ និងការងារផ្សេងទៀតនាពេលអនាគត។

# II. ខ្លឹមសារគតិយុត្តិ នៃមាត្រា១២

## មាត្រា១២ កថាខណ្ឌ១

១១. មាត្រា១២ កថាខណ្ឌ១ អះអាងជាថ្មីអំពីសិទ្ធិជនពិការដែលត្រូវបានទទួលស្គាល់ជាមនុស្សនៅចំពោះមុខច្បាប់។ មាត្រានេះ ធានាថា មនុស្សគ្រប់រូប ត្រូវបានគេគោរពជាបុគ្គលដែលមានបុគ្គលិកលក្ខណៈផ្លូវច្បាប់ ដែលជាតម្រូវការអាទិភាពសម្រាប់ការទទួលស្គាល់សមត្ថភាពខាងផ្នែកច្បាប់របស់បុគ្គល។

## មាត្រា១២ កថាខណ្ឌ២

១២. មាត្រា១២ កថាខណ្ឌ២ ទទួលស្គាល់ថា ជនពិការទទួលបានសមត្ថភាពខាងផ្នែកច្បាប់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃក្នុងគ្រប់ទិដ្ឋភាពនៃឆាកជីវិត។ សមត្ថភាពខាងផ្នែកច្បាប់ រួមមានសមត្ថភាពជាម្ចាស់សិទ្ធិ និងតួអង្គនៅក្រោមច្បាប់។ សមត្ថភាពខាងផ្នែកច្បាប់ក្នុងនាមជាម្ចាស់នៃសិទ្ធិផ្តល់ដល់បុគ្គល នូវការការពារសិទ្ធិរបស់ខ្លួនយ៉ាងពេញលេញពីប្រព័ន្ធច្បាប់។ សមត្ថភាពខាងផ្នែកច្បាប់ដើម្បីធ្វើសកម្មភាពតាមច្បាប់ ទទួលស្គាល់បុគ្គលជាភ្នាក់ងារមួយ ដោយមានអំណាចចូលរួមក្នុងកិច្ចការជំនួញ និងបង្កើត កែសម្រួល និងបញ្ចប់ទំនាក់ទំនងគតិយុត្តិ។ សិទ្ធិទទួលបានការទទួលស្គាល់ជាភ្នាក់ងារតាមផ្លូវច្បាប់ដែលមានចែងក្នុងមាត្រា១២ កថាខណ្ឌ៥ នៃអនុសញ្ញា ដែលរៀបរាប់អំពីភារកិច្ចរបស់រដ្ឋភាគីក្នុងការ "ចាត់វាល់វិធាការសមស្រប និងមានប្រសិទ្ធភាព

ដើម្បីធានាឲ្យជនពិការមានសិទ្ធិស្មើគ្នាក្នុងការធ្វើជាម្ចាស់ ឬទទួលមរតកលើទ្រព្យសម្បត្តិ ក្នុងការគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុផ្ទាល់ខ្លួន និងមានសិទ្ធិស្មើគ្នាចំពោះការខ្ចីឥណទានធនាគារ ការបញ្ចាំ និងទម្រង់ផ្សេងទៀតនៃឥណទានហិរញ្ញវត្ថុ ហើយ...ត្រូវធានាថាជនពិការមិនត្រូវបានគេដកហូតយកទ្រព្យសម្បត្តិតាមទំនើងចិត្តឡើយ″។

**១៣.** សមត្ថភាពខាងផ្នែកច្បាប់និងសមត្ថភាពផ្លូវចិត្តគឺជាទស្សនទានដោយឡែកពីគ្នា។ សមត្ថភាពខាងផ្នែកច្បាប់ គឺជាសមត្ថភាពក្នុងការកាន់កាប់សិទ្ធិ និងភារកិច្ច (ឋានៈតាមផ្លូវច្បាប់) និងជាសមត្ថភាពក្នុងការអនុវត្តសិទ្ធិ និងភារកិច្ចទាំងនោះ (ទីភ្នាក់ងារតាមផ្លូវច្បាប់)។ វាគឺជាគន្លឹះក្នុងការវាយតម្លៃប្រកបដោយអត្ថន័យក្នុងសង្គម។ សមត្ថភាពផ្លូវចិត្តសំដៅទៅលើជំនាញរបស់បុគ្គល ក្នុងការធ្វើការសម្រេចចិត្ត ដែលជាធម្មតាមានភាពខុសប្លែកគ្នាពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ហើយអាចខុសគ្នាសម្រាប់បុគ្គលណាម្នាក់អាស្រ័យទៅតាមកត្តាជាច្រើន ដោយរាប់បញ្ចូលទាំងកត្តាបរិស្ថាន និងសង្គម។ កាលពីអតីតកាល លិខិតុបករណ៍ច្បាប់ដូចជាសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស(មាត្រា៦), កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(មាត្រា១៦) និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (មាត្រា១៥) មិនបានបញ្ជាក់ច្បាស់អំពីភាពខុសគ្នារវាងសមត្ថភាពផ្លូវចិត្ត និងសមត្ថភាពផ្លូវច្បាប់ទេ។ ឥឡូវនេះ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ(មាត្រា១២) ចែងច្បាស់ថា ″ភាពទន់ខ្សោយនៃចិត្តគំនិត″ និងការហៅដែលមានលក្ខណៈរើសអើង មិនមែនជាហេតុផលស្របច្បាប់ សម្រាប់បដិសេធសមត្ថភាពខាងផ្នែកច្បាប់ (ឋានៈតាមផ្លូវច្បាប់ និងទីភ្នាក់ងារតាមផ្លូវច្បាប់) ឡើយ។

តាមមាត្រា១២ នៃអនុសញ្ញានេះ ភាពខ្វះខាតសមត្ថភាពផ្លូវចិត្តតាមជាក់ស្តែង ឬតាមការយល់ឃើញរបស់អ្នកដទៃ មិនត្រូវបានប្រើជាយុត្តិកម្មសម្រាប់ការបដិសេធសមត្ថភាពខាងផ្នែកច្បាប់ឡើយ។

១៤. សមត្ថភាពខាងផ្នែកច្បាប់ គឺជាសិទ្ធិមានជាប់ពីកំណើតមកដែលបានព្រមព្រៀងដោយមនុស្សទាំងអស់ដោយរាប់ទាំងជនពិការផង។ ដូចបានកត់សម្គាល់រួចមកហើយ គឺវាមានពីរផ្នែក។ ផ្នែកទីមួយ គឺឋានៈតាមផ្លូវច្បាប់ក្នុងការមានសិទ្ធិ ដែលត្រូវបានគេទទួលស្គាល់ជានីតិបុគ្គលនៅចំពោះមុខច្បាប់។ ឧទាហរណ៍ ឋានៈផ្លូវច្បាប់អាចរួមមាន ការមានសំបុត្រកំណើត ការស្វែងរកជំនួយវេជ្ជសាស្ត្រ ការចុះឈ្មោះដើម្បីមានតួនាទីក្នុងការបោះឆ្នោត ឬការដាក់ពាក្យសុំលិខិតឆ្លងដែនជាដើម។ ផ្នែកទីពីរ គឺជាទីភ្នាក់ងារតាមផ្លូវច្បាប់ក្នុងការធ្វើសកម្មភាពទៅលើសិទ្ធិទាំងនោះ និងការទទួលបានការទទួលស្គាល់សកម្មភាពទាំងនោះ ដោយច្បាប់។ គឺសមាសធាតុមួយនេះហើយ ដែលជារឿយៗត្រូវបានបដិសេធ ឬត្រូវបានកាត់បន្ថយសម្រាប់ជនពិការ។ ឧទាហរណ៍ ច្បាប់អាចអនុញ្ញាតិឲ្យជនពិការធ្វើជាម្ចាស់នៃទ្រព្យសម្បត្តិបាន ប៉ុន្តែ តែងតែមិនគោរពសកម្មភាពរបស់ពលរដ្ឋ ពាក់ព័ន្ធនឹងការទិញ និងលក់ទ្រព្យសម្បត្តិទេ។ តាមធម្មតាសមត្ថភាពខាងផ្នែកច្បាប់ មានន័យថា មនុស្សទាំងអស់ ដោយរាប់ទាំងជនពិការផង មានឋានៈតាមផ្លូវច្បាប់ និងមានទីភ្នាក់ងារតាមផ្លូវច្បាប់អាស្រ័យគុណធម៌របស់មនុស្ស។ ដូច្នេះ ផ្នែកទាំងពីរនៃសមត្ថភាពតាមផ្លូវច្បាប់ ត្រូវតែបានការទទួលស្គាល់ សម្រាប់សិទ្ធិទទួលបានសមត្ថភាពខាងផ្នែកច្បាប់ដែលត្រូវបំពេញ សម្រាប់ជនពិការ គឺសិទ្ធិទាំងនេះមិនអាចបំបែកចេញពីគ្នាបានឡើយ។

ទស្សនទានអំពីសមត្ថភាពផ្លូវចិត្តនេះមានវាទប្បដិវាទខ្លាំងណាស់ ដោយពិចារណាតែបទបញ្ញត្តិនេះផ្ទាល់តែប៉ុណ្ណោះ។ បញ្ញត្តិនេះមិនមានភាពច្បាស់លាស់ មិនមានលក្ខណៈវិទ្យាសាស្ត្រ និងមិនមែនជាបាតុភូតដែលកើតឡើងដោយធម្មជាតិ ដូចដែលត្រូវបានគេបង្ហាញជាហូរហែមកនោះទេ។ សមត្ថភាពផ្លូវចិត្តអាស្រ័យទៅលើបរិបទសង្គមនិងនយោបាយក៏ដូចជាអាស្រ័យទៅលើវិន័យវិជ្ជាជីវៈ និងការអនុវត្តដែលដើរតួនាទីដ៏ចម្បង ក្នុងការវាយតម្លៃអំពីសមត្ថភាពផ្លូវចិត្តនេះ។

១៥. ក្នុងរបាយការណ៍នៃរដ្ឋភាគីភាគច្រើនដែលគណៈកម្មាធិការបានពិនិត្យ រហូតមកទល់ពេលនេះ ទស្សនទានអំពីសមត្ថភាពផ្លូវចិត្ត និងសមត្ថភាពខាងផ្នែកច្បាប់នេះត្រូវបានដាក់បញ្ចូលគ្នា ដោយមានគោលបំណងថា ក្នុងករណីដែលបុគ្គលម្នាក់ត្រូវបានគេចាត់ទុកថា មានជំនាញអន់ខ្សោយក្នុងការសម្រេចចិត្ត ជាញឹកញាប់ ដោយសារតែពិការភាពផ្នែកគំនិត ឬចិត្តសង្គមហើយនោះ ជាលទ្ធផលសមត្ថភាពខាងផ្នែកច្បាប់របស់គាត់ ក្នុងការធ្វើការសម្រេចចិត្តជាក់លាក់ណាមួយនោះ ត្រូវបានគេដកហូតដែរ។ បញ្ហានេះគ្រាន់តែជាការសម្រេចចិត្តដោយឈរលើមូលដ្ឋាននៃការកំណត់រោគវិនិច្ឆ័យនៃភាពអន់ខ្សោយ (អភិក្រមអំពីស្ថានភាព) ឬក្នុងករណីដែលបុគ្គលម្នាក់ធ្វើការសម្រេចចិត្ត ដែលត្រូវគេចាត់ទុកថាមានលទ្ធផលអវិជ្ជមាន (អភិក្រមអំពីលទ្ធផល) ឬនៅក្នុងករណីដែលជំនាញក្នុងការសម្រេចចិត្តរបស់បុគ្គលណាម្នាក់នោះ ត្រូវគេចាត់ទុកថា មិនគ្រប់គ្រាន់ (អភិក្រមអំពីមុខងារ)។ អភិក្រមអំពីមុខងារប៉ុនប៉ងវាយតម្លៃអំពីសមត្ថភាពផ្លូវចិត្ត និងដើម្បីបដិសេធសមត្ថភាពខាងផ្នែកច្បាប់តាមការវាយតម្លៃនោះ។ ជារឿយៗ ដោយផ្អែកទៅលើថាតើបុគ្គលម្នាក់នោះ អាច

យល់អំពីលក្ខណៈ និងផលវិបាកនៃការសម្រេចចិត្តមួយដែរឬទេ និង/ឬថា តើគាត់អាចប្រើប្រាស់ ឬថ្លឹងថ្លែងព័ត៌មានពាក់ព័ន្ធបានដែរឬទេ។ អភិក្រម អំពីមុខងារនេះនៅមានចន្លោះប្រហោងដោយសារហេតុផលសំខាន់ពីរៈ

(ក). វាត្រូវយកមកអនុវត្តដោយរើសអើងទៅលើជនពិការ និង

(ខ). វាត្រូវបានសន្មត់ទុកជាមុនថា អាចវាយតម្លៃបានដោយត្រឹមត្រូវទៅលើដំណើរការខាងក្នុងរបស់ចិត្តមនុស្ស ហើយនៅពេលបុគ្គលនោះមិនបានជាប់ក្នុងការវាយតំលៃ ជាបន្ទាប់នឹងត្រូវបដិសេធសិទ្ធិមនុស្សស្នូលរបស់ពួកគាត់តែម្តង - គឺសិទ្ធិទទួលបានការទទួលស្គាល់ដោយស្មើភាពគ្នានៅចំពោះមុខច្បាប់។ នៅក្នុងអភិក្រមទាំងអស់នេះ ពិការភាពរបស់បុគ្គល និង/ឬជំនាញក្នុងការធ្វើសេចក្តីសម្រេចចិត្តត្រូវបានគេយកធ្វើជាមូលដ្ឋានស្របច្បាប់ សម្រាប់បដិសេធសមត្ថភាពខាងផ្នែកច្បាប់របស់គេ និងបន្ទាបឋានៈរបស់គាត់ក្នុងនាមជាមនុស្សនៅចំពោះមុខច្បាប់។ មាត្រា ១២ មិនអនុញ្ញាតិឲ្យមានការបដិសេធ ដោយការរើសអើងបែបនេះទៅលើសមត្ថភាពខាងផ្នែកច្បាប់ឡើយ ប៉ុន្តែ ជាប្រការកាន់តែប្រសើរ មាត្រានេះតម្រូវឲ្យមានការផ្តល់ការគាំទ្រ ក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់នេះ។

## មាត្រា១២ កថាខណ្ឌ៣

១៦. មាត្រា១២ កថាខណ្ឌ៣ ទទួលស្គាល់ថារដ្ឋភាគីមានកាតព្វកិច្ច ដើម្បីផ្តល់លទ្ធភាពឲ្យជនពិការក្នុងការទទួលបានការជួយគាំទ្រ ក្នុងការអនុវត្តសមត្ថភាពខាងផ្នែកច្បាប់របស់ខ្លួន។ រដ្ឋភាគីត្រូវតែជៀសឲ្យផុត

ពីការបដិសេធជនពិការមិនឲ្យទទួលបាននូវសមត្ថភាពផ្នែកច្បាប់របស់ខ្លួន ហើយផ្ទុយមកវិញ រដ្ឋភាគីត្រូវតែផ្តល់ដល់ជនពិការក្នុងការទទួលបាននូវការជួយគាំទ្រចាំបាច់ ដើម្បីជួយឲ្យពួកគេអាចធ្វើការសម្រេចចិត្ត ដែលមានឥទ្ធិពលតាមផ្លូវច្បាប់។

**១៧.** ការគាំទ្រក្នុងការអនុវត្តសមត្ថភាពខាងផ្នែកច្បាប់ ត្រូវតែគោរពដល់សិទ្ធិ ឆន្ទៈ និងចំណង់ចំណូលចិត្តរបស់ជនពិការ និងមិនត្រូវមានតម្លៃស្មើនឹងការសម្រេចចិត្តជំនួសឡើយ។ មាត្រា១២ កថាខណ្ឌ៣ មិនបានបញ្ជាក់ឲ្យច្បាស់ ថាតើទម្រង់បែបណានៃការជួយឧបត្ថម្ភបែបណាគួរផ្តល់ឲ្យ។ "ការជួយឧបត្ថម្ភ" ជាពាក្យទូលំទូលាយមួយដែលក្តោបទាំងការរៀបចំការជួយឧបត្ថម្ភទាំងផ្លូវការនិងមិនផ្លូវការដែលមានប្រភេទផ្សេងគ្នា និងកម្រិតស៊ីជម្រៅផ្សេងគ្នា។ ឧទាហរណ៍ ជនពិការអាចជ្រើសរើសបុគ្គលសម្រាប់ការជួយឧបត្ថម្ភដែលទុកចិត្តម្នាក់ ឬច្រើននាក់ ក្នុងការជួយពួកគេក្នុងការអនុវត្តសមត្ថភាពខាងផ្នែកច្បាប់សម្រាប់ប្រភេទនៃការសម្រេចចិត្តមួយចំនួន ឬអាចអំពាវនាវឲ្យមានការជួយឧបត្ថម្ភតាមទម្រង់ផ្សេងៗ ដូចជាការគាំទ្រពីមិត្តភក្តិ ការតស៊ូមតិ (រួមទាំងការជួយឧបត្ថម្ភសម្រាប់ការតស៊ូមតិផ្ទាល់ខ្លួន)ឬជំនួយក្នុងការប្រាស្រ័យទាក់ទង។ ការជួយឧបត្ថម្ភដល់ជនពិការក្នុងការអនុវត្តសមត្ថភាពខាងផ្នែកច្បាប់ ជារួម អាចមានវិធានការពាក់ព័ន្ធនឹងការរចនាប្លង់ជាសកល និងការបង្កលក្ខណៈងាយស្រួល - ឧទា. ការទាមទារឲ្យតួអង្គឯកជន និងសាធារណៈ រួមមានស្ថាប័នធនាគារ និងស្ថាប័នហិរញ្ញវត្ថុក្នុងការផ្តល់ព័ត៌មាន ដែលអាចយល់បាន ឬផ្តល់ការបកប្រែភាសាសញ្ញា ដែលមានជំនាញវិជ្ជាជីវៈ - ក្នុងគោលបំណង

ដើម្បីជួយឲ្យជនពិការអាចបំពេញសកម្មភាពផ្លូវច្បាប់ដែលចាំបាច់សម្រាប់ការបើកគណនេយ្យធនាគារ ចុះកិច្ចសន្យា ឬដំណើរការកិច្ចការជំនួញសង្គមផ្សេងៗទៀត។ ការជួយឧបត្ថម្ភ ក៏អាចបង្កើតឲ្យមានការអភិវឌ្ឍន៍ និងការទទួលស្គាល់ទៅលើវិធីសាស្ត្រទំនាក់ទំនងចម្រុះផ្សេងគ្នាដែលមិនមានក្នុងអនុសញ្ញា ជាពិសេស សម្រាប់អ្នកដែលប្រើទម្រង់នៃការទាក់ទងដែលមិនចេញវាចា ដើម្បីសំដែងអំពីឆន្ទៈ និងការពេញចិត្តរបស់ខ្លួន។ សម្រាប់ជនពិការជាច្រើន សមត្ថភាពក្នុងការធ្វើផែនការទុកជាមុន គឺជាទម្រង់នៃការជួយឧបត្ថម្ភដ៏សំខាន់មួយ ដែលពួកគេអាចសម្តែងអំពីឆន្ទៈ និងការពេញចិត្តរបស់ខ្លួន ដែលត្រូវអនុវត្តតាមនៅពេលណាមួយ ដែលពួកគេមិនស្ថិតក្នុងស្ថានភាពមួយ ដើម្បីប្រាប់ឲ្យដឹងអំពីសេចក្តីប្រាថ្នារបស់ខ្លួនទៅអ្នកដទៃទៀតបាន។ ជនពិការទាំងអស់មានសិទ្ធិចូលរួមក្នុងការធ្វើផែនការទុកជាមុន និងគួរទទួលបានឱកាសក្នុងការធ្វើដូច្នេះ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។ ជម្រើសមួយនៃទម្រង់ផ្សេងៗសម្រាប់យន្តការធ្វើផែនការជាមុននោះ អាចផ្តល់ដោយរដ្ឋភាគីក្នុងការសម្រួលដល់ការពេញចិត្តផ្សេងៗ ប៉ុន្តែ ជម្រើសទាំងអស់គួរតែមិនមានភាពរើសអើងទេ។ ការជួយឧបត្ថម្ភគួរផ្តល់ឲ្យបុគ្គលណាដែលប្រាថ្នាចង់បំពេញដំណើរការធ្វើផែនការទុកជាមុននេះ។ ចំណុចមួយដែលការណែនាំទុកជាមុននោះ ត្រូវចូលជាធរមាន (និងលែងមានប្រសិទ្ធភាព) គប្បីត្រូវបានសម្រេចដោយបុគ្គល និងមានចែងនៅក្នុងអត្ថបទនៃការណែនាំនោះ ហើយមិនគួរត្រូវផ្អែកតែទៅលើការវាយតម្លៃណាមួយថាបុគ្គលនោះខ្វះសមត្ថភាពផ្លូវចិត្តឡើយ។

១៨. ប្រភេទនិងកម្រិតស៊ីជម្រៅនៃការជួយឧបត្ថម្ភដែលត្រូវផ្ដល់ឲ្យ នឹងខុសប្លែកពីគ្នាគួរឲ្យកត់សម្គាល់ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ដោយអាស្រ័យទៅលើភាពចម្រុះគ្នានៃជនពិការដែរ។ ចំណុចនេះ ស្រប តាមមាត្រា៣(ឃ) ដែលចែងអំពី "ការគោរពជនពិការខុសៗគ្នា និងការទទួលស្គាល់ជនពិការជាផ្នែកមួយនៃភាពចម្រុះរបស់មនុស្ស និងមនុស្សជាតិ" ជាគោលការណ៍ទូទៅមួយក្នុងអនុសញ្ញា។ នៅគ្រប់ពេលទាំងអស់ ដោយរាប់ទាំងពេលស្ថានភាពមានវិបត្តិផងនោះ ស្វ័យភាពបុគ្គល និង សមត្ថភាពរបស់ជនពិការ ក្នុងការធ្វើសេចក្ដីសម្រេចចិត្តត្រូវតែទទួលបាន ការគោរព។

១៩. ជនពិការមួយចំនួន ត្រឹមតែស្វែងរកការទទួលស្គាល់សិទ្ធិរបស់ពួកគេក្នុងការទទួលបាននូវសមត្ថភាពខាងផ្នែកច្បាប់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ដែលមានចែងបន្ថែមក្នុងមាត្រា ១២ កថាខណ្ឌ២ ប៉ុណ្ណោះ ហើយក៏មិនប្រាថ្នាប្រើប្រាស់សិទ្ធិទទួលបាន ការជួយឧបត្ថម្ភដូចមានចែងក្នុងមាត្រា១២ កថាខណ្ឌ៣ឡើយ។

## មាត្រា១២ កថាខណ្ឌ៤

២០. មាត្រា១២ កថាខណ្ឌ៤ គូសបញ្ជាក់អំពីកិច្ចធានាការពារដែលត្រូវតែមាន នៅក្នុងប្រព័ន្ធជួយឧបត្ថម្ភមួយ ក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់។ មាត្រា១២ កថាខណ្ឌ៤ ត្រូវតែអានរួមជាមួយនឹង កថាខណ្ឌផ្សេងទៀតនៃមាត្រា១២ និងជាមួយអនុសញ្ញាទាំងមូល។ បទប្បញ្ញត្តិនេះតម្រូវឲ្យរដ្ឋភាគីបង្កើតកិច្ចធានាការពារសមស្រប និងមាន

ប្រសិទ្ធភាពមួយ សម្រាប់ការប្រើប្រាស់សមត្ថភាពផ្នែកច្បាប់។ គោលបំណងចម្បងនៃកិច្ចធានាការពារទាំងនេះ ត្រូវតែធានាឲ្យមានការគោរពសិទ្ធិ ឆន្ទៈ និងចំណង់ចំណូលចិត្តរបស់បុគ្គល។ ដើម្បីសម្រេចគោលបំណងនេះបាន កិច្ចធានាការពារត្រូវតែផ្តល់ការការពារពីការរំលោភបំពានដោយឈរលើមូលដ្ឋាននៃភាពស្មើគ្នាជាមួយអ្នកដទៃ។

**២១.** បន្ទាប់ពីមានកិច្ចខិតខំប្រឹងប្រែងគួរឲ្យកត់សំគាល់ ក្នុងការកំណត់អំពីឆន្ទៈ និងចំណង់ចំណូលចិត្តរបស់បុគ្គលណាមួយបាននោះ "ការបកស្រាយដ៏ប្រសើរបំផុតសម្រាប់ពាក្យឆន្ទៈ និងចំណង់ចំណូលចិត្ត" ត្រូវជំនួសការកំណត់អំពី "ឧត្តមប្រយោជន៍"។ ទង្វើនេះ គោរពដល់សិទ្ធិ ឆន្ទៈ និងចំណង់ចំណូលចិត្តរបស់បុគ្គល ស្របតាមមាត្រា១២(៤)។ គោលការណ៍ "ឧត្តមប្រយោជន៍" មិនមែនជាកិច្ចធានាការពារដែលអនុលោមតាមមាត្រា១២ ពាក់ព័ន្ធនឹងមនុស្សពេញវ័យនោះទេ។ បទដ្ឋាននៃ "ឆន្ទៈ និងចំណង់ចំណូលចិត្ត" ត្រូវជំនួសដោយបទដ្ឋាន "ឧត្តមប្រយោជន៍" ដើម្បីធានាថាជនពិការទទួលបានសិទ្ធិ ក្នុងការទទួលបានសមត្ថភាពខាងផ្នែកច្បាប់ ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ។

**២២.** មនុស្សទាំងអស់ដែលប្រឈមនឹងហានិភ័យក្នុងការ "ទទួលរងឥទ្ធិពលហួសកម្រិត" ប៉ុន្តែប្រការនេះអាចកាន់តែមានសភាពអាក្រក់ឡើង សម្រាប់អ្នកដែលត្រូវពឹងផ្អែកលើការជួយឧបត្ថម្ភពីអ្នកដទៃ ក្នុងការធ្វើការសម្រេចចិត្ត។ លក្ខណៈកំណត់អំពីការទទួលរងនូវឥទ្ធិពលហួសកម្រិត កាលណាគុណភាពនៃអន្តរកម្មរវាងបុគ្គល ផ្តល់ការជួយឧបត្ថម្ភ និងបុគ្គលទទួលការជួយឧបត្ថម្ភ រួមមានសញ្ញានៃការភ័យខ្លាច ការឈ្លាន

ពាន ការគំរាមកំហែង ការបំភាន់ ឬការបោកបញ្ឆោត។ កិច្ចធានាការពារសម្រាប់ការអនុវត្តសមត្ថភាពខាងផ្នែកច្បាប់ ត្រូវរាប់បញ្ចូលទាំងការការពារប្រឆាំងនឹងការទទួលរងនូវឥទ្ធិពលហួសកម្រិត ក៏ប៉ុន្តែ ការការពារត្រូវតែគោរពសិទ្ធិ ឆន្ទៈ និងចំណង់ចំណូលចិត្តរបស់បុគ្គលផងដែរ ដោយគិតទាំងសិទ្ធិក្នុងការប្រឈមទៅនឹងហានិភ័យ និងសិទ្ធិក្នុងការមានកំហុស។

## មាត្រា១២ កថាខណ្ឌ៥

**២៣.** មាត្រា១២ កថាខណ្ឌ៥ តម្រូវឲ្យរដ្ឋភាគីចាត់វាល់វិធានការដូចជាវិធានការផ្នែកច្បាប់ ផ្នែករដ្ឋបាល ផ្នែកតុលាការ និងវិធានការជាក់ស្តែងផ្សេងទៀតឲ្យបានសមស្រប និងមានប្រសិទ្ធភាព ដើម្បីធានាឲ្យបាននូវសិទ្ធិរបស់ជនពិការ ពាក់ព័ន្ធនឹងកិច្ចការហិរញ្ញវត្ថុ និងកិច្ចការសេដ្ឋកិច្ច ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។ សិទ្ធិទទួលបានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ តាមទំនៀមទំលាប់តែងត្រូវបានបដិសេធមិនឲ្យទៅជនពិការ ដោយផ្អែកលើគម្រូវេជ្ជសាស្ត្រនៃពិការភាព។ អភិក្រមនៃការបដិសេធសមត្ថភាពខាងផ្នែកច្បាប់របស់ជនពិការ ទៅលើបញ្ហាហិរញ្ញវត្ថុ ត្រូវតែជំនួសដោយការជួយឧបត្ថម្ភទាំងឡាយ ដើម្បីឲ្យជនពិការអាចប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់បាន ដោយយោងតាមមាត្រា១២ កថាខណ្ឌ៣។ តាមវិធីសាស្ត្រដូចគ្នាដែរ ដោយសារតែគេមិនអាចយកបញ្ហាយេនឌ័រទៅធ្វើជាមូលដ្ឋានសម្រាប់ការរើសអើងក្នុងវិស័យហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិនោះ ព្រមទាំងមិនអាចប្រើពិការភាពជាមូលដ្ឋាននៃការរើសអើងដែរ។

## III. ភាតព្វកិច្ចរបស់រដ្ឋភាគី

**២៤.** រដ្ឋភាគីមានកាតព្វកិច្ចក្នុងការគោរព ការពារ និងបំពេញសិទ្ធិជនពិការទាំងអស់ ក្នុងការទទួលបាននូវការទទួលស្គាល់ដោយស្មើភាពនៅចំពោះមុខច្បាប់។ ក្នុងន័យនេះ រដ្ឋភាគីគួររារាំងសកម្មភាពណាមួយដែលដកហូតសិទ្ធិជនពិការ ក្នុងការទទួលបានការទទួលស្គាល់ដោយស្មើភាពគ្នានៅចំពោះមុខច្បាប់។ រដ្ឋភាគីគួរចាត់វិធានការ ដើម្បីទប់ស្កាត់តួអង្គមិនមែនរដ្ឋ និងបុគ្គលឯកជន ក្នុងការជ្រៀតជ្រែកទៅលើសមត្ថភាពរបស់ជនពិការ ក្នុងការសម្រេចបាន និងទទួលសិទ្ធិមនុស្សរបស់ពួកគេដោយរាប់បញ្ចូលទាំងសមត្ថភាពខាងផ្នែកច្បាប់ផងដែរ។ គោលបំណងមួយក្នុងចំណោមគោលបំណងនានានៃការជួយឧបត្ថម្ភ ក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់នេះគឺការកសាងទំនុកចិត្ត និងជំនាញរបស់ជនពិការ ដើម្បីឲ្យពួកគេអាចប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់របស់ខ្លួនបាន ដោយមានការគាំទ្រកាន់តែតិចទៅ ក្នុងពេលអនាគត ប្រសិនបើពួកគេចង់បានដូច្នេះ។ រដ្ឋភាគីមានកាតព្វកិច្ច ក្នុងការផ្តល់ការបណ្តុះបណ្តាលសម្រាប់បុគ្គលដែលទទួលបានការជួយឧបត្ថម្ភ ដើម្បីឲ្យពួកគេអាចសម្រេចចិត្តនៅពេល ដែលពួកគេត្រូវការការជួយឧបត្ថម្ភតិចជាងមុន ឬនៅពេលណាដែលពួកគេលែងត្រូវការការជួយឧបត្ថម្ភ ក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់របស់ពួកគេ។

**២៥.** ដើម្បីទទួលស្គាល់ "សមត្ថភាពខាងផ្នែកច្បាប់ជាសាកល" ឲ្យបានពេញលេញ ដោយហេតុថា បុគ្គលទាំងអស់(ដោយមិនគិតពីពិការភាព ឬជំនាញក្នុងការសម្រេចចិត្ត) មានសមត្ថភាពខាងផ្នែកច្បាប់ ពី

កំណើតមកនោះ រដ្ឋភាគីត្រូវលុបបំបាត់ចោលការបដិសេធទាំងឡាយលើសមត្ថភាពខាងផ្នែកច្បាប់ ដែលមានលក្ខណៈរើសអើង ដោយឈរលើមូលដ្ឋាននៃពិការភាពដោយចេតនា ឬដោយធរមាន។

**២៦.** នៅក្នុងសេចក្តីសង្កេតសន្និដ្ឋាន ពាក់ព័ន្ធនឹងមាត្រា១២ គណៈកម្មាធិការស្តីពីសិទ្ធិជនពិការបានបញ្ជាក់ដដែលឡើងវិញថា រដ្ឋភាគីពាក់ព័ន្ធត្រូវតែ "ពិនិត្យឡើងវិញទៅលើច្បាប់ដែលអនុញ្ញាតិឲ្យមានភាពជាអាណាព្យាបាល និងភាពជាអ្នកគ្រប់គ្រង និងត្រូវតែចាត់វិធានការក្នុងការរៀបចំបង្កើតច្បាប់ និងគោលនយោបាយនានាដើម្បីជំនួសរបបនៃការធ្វើការសម្រេចចិត្តជំនួស ដោយការសម្រេចចិត្តដែលមានការគាំទ្រ ដែលជាការគោរពដល់ស្វ័យភាព ឆន្ទៈ និងចំណង់ចំណូលចិត្តរបស់បុគ្គលវិញ"។

**២៧.** របបនៃការធ្វើសេចក្តីសម្រេចចិត្តជំនួស អាចមានទម្រង់ផ្សេងៗគ្នាជាច្រើន ដោយរាប់បញ្ចូលទាំងភាពជាអាណាព្យាបាលទាំងស្រុង គំហាត់ខាងផ្នែកតុលាការ និងភាពជាអាណាព្យាបាលដោយអន្លើ។ ក៏ប៉ុន្តែ របបទាំងនេះមានលក្ខណៈដូចគ្នាជាក់លាក់មួយចំនួន៖ គេអាចកំណត់របបទាំងនេះថា ជាប្រព័ន្ធនានាដែល

(i) សមត្ថភាពខាងផ្នែកច្បាប់ត្រូវបានគេដកហូតពីបុគ្គលម្នាក់ សូម្បីតែសមត្ថភាពនេះពាក់ព័ន្ធទៅនឹងការសម្រេចតែមួយក៏ដោយ

(ii) អ្នកធ្វើសេចក្តីសម្រេចចិត្តជំនួសត្រូវបានចាត់តាំងឡើងដោយបុគ្គលណាម្នាក់ទៀត ដែលមិនមែនជាបុគ្គលពាក់ព័ន្ធ ហើយការធ្វើសេចក្តីសម្រេចចិត្តនេះអាចធ្វើឡើយផ្ទុយពីឆន្ទៈរបស់បុគ្គល ឬ

(iii) ការធ្វើសេចក្តីសម្រេចចិត្តណាមួយ ដែលធ្វើឡើងដោយអ្នកធ្វើសេចក្តីសម្រេចចិត្តជំនួសនោះ ផ្អែកទៅលើអ្វីដែលគេជឿថាធ្វើឡើងក្នុងទិសដៅ "ឧត្តមប្រយោជន៍" របស់បុគ្គលពាក់ព័ន្ធ គឺផ្ទុយពីការពឹងផ្អែកទៅលើឆន្ទៈនិងចំណង់ចំណូលចិត្តផ្ទាល់របស់បុគ្គលនោះ។

**២៨.** កាតព្វកិច្ចរបស់រដ្ឋភាគី ក្នុងការជំនួសនូវរបបនៃការធ្វើសេចក្តីសម្រេចចិត្តជំនួស ដោយដាក់ជំនួសមកវិញនូវការធ្វើសេចក្តីសម្រេចចិត្តដោយមានការគាំទ្រ ទាមទារឲ្យមានទាំងការលុបបំបាត់របបនៃការធ្វើសេចក្តីសម្រេចចិត្តជំនួស និងទាំងការរៀបចំបង្កើតជម្រើសនៃការធ្វើសេចក្តីសម្រេចចិត្តដែលមានការគាំទ្រវិញ។ ការរៀបចំបង្កើតប្រព័ន្ធនៃការធ្វើសេចក្តីសម្រេចចិត្ត ដែលមានការគាំទ្រ ស្របជាមួយនឹងការរក្សារបបនៃការធ្វើសេចក្តីសម្រេចចិត្តជំនួស មិនមានលក្ខណៈគ្រប់គ្រាន់ ដោយអនុលោមតាមមាត្រា១២ នៃអនុសញ្ញានេះទេ។

**២៩.** របបនៃការធ្វើសេចក្តីសម្រេចចិត្តដែលមានការគាំទ្រ រួមមានជម្រើសគាំទ្រផ្សេងៗដែលផ្តល់នូវភាពលើសលុបដល់ឆន្ទៈ និងចំណង់ចំណូលចិត្តរបស់បុគ្គល និងគោរពបទដ្ឋានសិទ្ធិមនុស្ស។ របបនេះគួរត្រូវផ្តល់ការការពារទៅលើសិទ្ធិទាំងអស់ ដោយរាប់បញ្ចូលទាំងសិទ្ធិទាក់ទងនឹងស្វ័យភាព (សិទ្ធិមានសមត្ថភាពខាងផ្នែកច្បាប់ សិទ្ធិទទួលបានការទទួលស្គាល់ដោយស្មើភាពគ្នានៅចំពោះមុខច្បាប់ សិទ្ធិក្នុងការជ្រើសរើសកន្លែងរស់នៅជាដើម) ព្រមទាំង សិទ្ធិពាក់ព័ន្ធនឹងសេរីភាពរួចផុតពីការរំលោភបំពាន និងការប្រព្រឹត្តមកលើខ្លួនដោយមិនគប្បី (សិទ្ធិរស់រានមាន

ជីវិត សិទ្ធិទទួលបានសុចរិតភាពនៃរាងកាយ។ល។)។ លើសពីនេះទៀត ប្រព័ន្ធនៃការធ្វើសេចក្តីសម្រេចចិត្ត ដែលមានការគាំទ្រ មិនគួរដាក់កម្រិតជ្រុលពេកទៅលើជីវភាពរបស់ជនពិការឡើយ។ រីឯរបបនៃការធ្វើសេចក្តីសម្រេចចិត្តដែលមានការគាំទ្រនេះ អាចមានទម្រង់ជាច្រើនក៏ដោយ ក៏គ្រប់ទម្រង់ទាំងអស់គួរត្រូវបញ្ចូលបទប្បញ្ញត្តិសំខាន់ៗ ដើម្បីធានាឲ្យមានការអនុវត្តតាមមាត្រា១២ នៃអនុសញ្ញានេះ ក្នុងនោះរួមមានដូចខាងក្រោម៖

(ក) ការធ្វើសេចក្តីសម្រេចចិត្ត ដែលមានការគាំទ្រ ត្រូវតែផ្តល់ឲ្យសម្រាប់មនុស្សគ្រប់រូប។ កម្រិតនៃតម្រូវការការគាំទ្ររបស់បុគ្គលណាមួយ (ជាពិសេសនៅពេលដែលតម្រូវការនោះមានកម្រិតខ្ពស់) មិនគួរជាឧបសគ្គ ក្នុងការទទួលបានការគាំទ្រ ក្នុងការធ្វើសេចក្តីសម្រេចចិត្តនោះទេ

(ខ) រាល់ទម្រង់ទាំងអស់នៃការគាំទ្រ ក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់ (ដោយរាប់បញ្ចូលទាំងទម្រង់នៃការគាំទ្រល្អិតល្អន់នានាផងនោះ) ត្រូវតែផ្អែកទៅលើឆន្ទៈ និងចំណង់ចំណូលចិត្តរបស់បុគ្គល គឺមិនមែនផ្អែកទៅលើអ្វីដែលគេយល់ថា ក្នុងទិសដៅនៃឧត្តមប្រយោជន៍របស់បុគ្គលនោះទេ

(គ) វិធីប្រើសម្រាប់ទំនាក់ទំនងរបស់បុគ្គល មិនត្រូវក្លាយទៅជាឧបសគ្គ ក្នុងការទទួលបានការគាំទ្រក្នុងការធ្វើសេចក្តីសម្រេចចិត្តឡើយ សូម្បីតែក្នុងករណីដែលការទំនាក់ទំនងសាមញ្ញ ឬមានមនុស្សតិចតួចអាចយល់បានក៏ដោយ

(ឃ) ការទទួលស្គាល់តាមច្បាប់ ទៅលើអ្នកផ្តល់ការគាំទ្រជ្រើសរើសជាផ្លូវការដោយបុគ្គលណាម្នាក់ ត្រូវតែអាចរកបាន និងត្រូវតែមានការបង្កលក្ខណៈងាយស្រួល ហើយរដ្ឋត្រូវមានកាតព្វកិច្ច ក្នុងការសម្រួលដល់ការបង្កើតការគាំទ្រនេះ ជាពិសេស សម្រាប់មនុស្សដែលស្ថិតនៅឯកោ ហើយមិនអាចប្រើប្រាស់បាននូវការគាំទ្រកើតឡើង ដោយធម្មជាតិក្នុងសហគមន៍មនុស្ស ដែលមិនអាចទទួលបានការគាំទ្រដែលមានស្រាប់ទាំងឡាយ ក្នុងសហគមន៍របស់ពួកគាត់។ បញ្ហានេះ ត្រូវតែរាប់បញ្ចូលទាំងយន្តការសម្រាប់ភាគីទីបីក្នុងការផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកផ្តល់ការគាំទ្រ ក៏ដូចជាយន្តការសម្រាប់ភាគីទីបី ក្នុងការតបតជំទាស់ទៅនឹងសកម្មភាពរបស់អ្នកផ្តល់ការគាំទ្រ ប្រសិនបើគេជឿជាក់ថា អ្នកផ្តល់ការគាំទ្រនោះមិនកំពុងដើរតួនាទីដែលផ្អែកទៅលើឆន្ទៈ និងចំណង់ចំណូលចិត្តរបស់បុគ្គលពាក់ព័ន្ធទេ

(ង) ដើម្បីអនុវត្តតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងមាត្រា១២ កថាខណ្ឌ១៣ នៃអនុសញ្ញាថា រដ្ឋភាគីត្រូវតែចាត់វិធានការនានាក្នុង "ការផ្តល់ការទទួលបាន" ការគាំទ្រដែលគេទាមទារនោះ រដ្ឋភាគីត្រូវតែធានាឲ្យមានការគាំទ្រដែលអាចរកបានក្នុងតម្លៃតិចបំផុត ឬមិនគិតថ្លៃ ទៅដល់ជនពិការ ហើយថា កង្វះខាតធនធានហិរញ្ញវត្ថុមិនត្រូវក្លាយជាឧបសគ្គ ក្នុងការទទួលបានការគាំទ្រ ក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់ឡើយ

(ច) គេមិនត្រូវយកការគាំទ្រក្នុងការធ្វើសេចក្ដីសម្រេចចិត្តទៅប្រើជាយុត្តិកម្ម សម្រាប់ដាក់កំហិតទៅលើសិទ្ធិជាមូលដ្ឋានដទៃទៀតរបស់ជនពិការបានទេ ជាពិសេស សិទ្ធិបោះឆ្នោត សិទ្ធិរៀបការ (ឬសិទ្ធិបង្កើតភាពជាដៃគូរបស់ពលរដ្ឋ) និងសិទ្ធិបង្កើតគ្រួសារ សិទ្ធិបន្តពូជ សិទ្ធិជាឪពុកម្ដាយ សិទ្ធិផ្ដល់ការយល់ព្រមសម្រាប់ទំនាក់ទំនងស្និទ្ធស្នាល និងយល់ព្រមក្នុងការទទួលបានការព្យាបាលវេជ្ជសាស្ត្រ និងសិទ្ធិមានសេរីភាព

(ឆ) បុគ្គលត្រូវតែមានសិទ្ធិក្នុងការបដិសេធមិនទទួលយកការគាំទ្រ និងរំលាយ ឬផ្លាស់ប្ដូរទំនាក់ទំនងនៃការគាំទ្រនេះបានគ្រប់ពេលវេលា

(ជ) កិច្ចធានាការពារត្រូវតែបង្កើតឡើង សម្រាប់គ្រប់ដំណើរការទាំងអស់ ពាក់ព័ន្ធនឹងសមត្ថភាពខាងផ្នែកច្បាប់ និងការគាំទ្រទាំងឡាយ ក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់។ គោលដៅនៃកិច្ចធានាការពារ គឺដើម្បីធានាថា ឆន្ទៈ និងចំណង់ចំណូលរបស់បុគ្គលត្រូវទទួលបាននូវការគោរព

(ឈ) ការផ្ដល់ការគាំទ្រដល់ការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់មិនគួរផ្អែកទៅលើការវាយតម្លៃសមត្ថភាពផ្លូវចិត្តឡើយ។ ដូច្នេះហើយ គេទាមទារឲ្យមានសូចនាករថ្មីៗ ដែលគ្មានការរើសអើងសម្រាប់សេចក្ដីត្រូវការក្នុងការគាំទ្រនេះ សម្រាប់ការផ្ដល់ការគាំទ្រក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់។

៣០. សិទ្ធិទទួលបានសមភាពនៅចំពោះមុខច្បាប់ ត្រូវបានទទួលស្គាល់ជាយូរយារណាស់មកហើយ ជាសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយមានឫសគល់នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមានជាប់មកភ្លាមនៅពេលផ្តល់សច្ចាប័ន ហើយរដ្ឋភាគីត្រូវចាត់វិធានការដើម្បីសម្រេចបាននូវសិទ្ធិទាំងនោះជាបន្ទាន់។ ហេតុដូច្នេះហើយ សិទ្ធិទាំងឡាយដែលមានចែងក្នុងមាត្រា១២ ត្រូវអនុវត្តភ្លាមនៅពេលដែលផ្តល់សច្ចាប័ន និងត្រូវធ្វើឲ្យសម្រេចជាបន្ទាន់ដែរ។ កាតព្វកិច្ចរបស់រដ្ឋក្នុងការផ្តល់ការទទួលបាននូវការគាំទ្រ សម្រាប់ការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់ក្នុងមាត្រា១២(៣) គឺជាកាតព្វកិច្ចរបស់រដ្ឋ ដែលត្រូវតែធ្វើ ដើម្បីបំពេញសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក្នុងការទទួលបានការទទួលស្គាល់ដោយស្មើភាពគ្នានៅចំពោះមុខច្បាប់។ ការសម្រេចឲ្យបាននូវភាពជឿនលឿនជាលំដាប់ (មាត្រា៤ កថាខណ្ឌ២) មិនបានអនុវត្តចំពោះមាត្រា១២ នោះទេ។ នៅពេលផ្តល់សច្ចាប័ន រដ្ឋភាគីត្រូវតែចាប់ផ្តើមជាបន្ទាន់ក្នុងការចាត់វិធានការនានាសំដៅសម្រេចឲ្យបាននូវសិទ្ធិទាំងឡាយក្នុងមាត្រា១២នេះ។ វិធានការទាំងនេះត្រូវតែធ្វើឡើងដោយប្រយ័ត្នប្រយែង មានផែនការល្អ និងបញ្ចូលការពិគ្រោះយោបល់ និងការចូលរួមប្រកបដោយអត្ថន័យពីជនពិការ និងអង្គការជនពិការ។

# IV. ទំនាក់ទំនងជាមួយបទប្បញ្ញត្តិផ្សេងទៀតនៃអនុសញ្ញា

៣១. ការទទួលស្គាល់សមត្ថភាពខាងផ្នែកច្បាប់ជាប់ទាក់ទងគ្នាមិនអាចញែកដាច់ជាមួយនឹងការទទួលបាន សិទ្ធិមនុស្សដទៃផ្សេងទៀតដែលមានចែងក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ មានដូចជា តែមិនកំរិតចំពោះសិទ្ធិទទួលបានយុត្តិធម៌ (មាត្រា១៣) សិទ្ធិមានសេរីភាពរួចផុតពីការឃុំខ្លួនដោយអចេតនា នៅកន្លែងព្យាបាលសុខភាពផ្លូវចិត្ត និងមិនត្រូវបានបង្ខំឲ្យទទួលការព្យាបាលសុខភាពផ្លូវចិត្ត (មាត្រា១៤) សិទ្ធិទទួលបានការគោរពសុចរិតភាពផ្លូវកាយ និងផ្លូវចិត្តរបស់បុគ្គល (មាត្រា១៧) សិទ្ធិសេរីភាពនៃការធ្វើដំណើរ និងការទទួលបានសញ្ជាតិ (មាត្រា១៨) សិទ្ធិក្នុងការជ្រើសរើសកន្លែងរស់នៅ និងអ្នកត្រូវរស់នៅជាមួយ (មាត្រា១៩) សិទ្ធិមានសេរីភាពក្នុងការបញ្ចេញមតិ (មាត្រា២១) សិទ្ធិរៀបការ និងបង្កើតគ្រួសារ (មាត្រា២៣) សិទ្ធិផ្តល់ការយល់ព្រមក្នុងការទទួលការព្យាបាលវេជ្ជសាស្ត្រ (មាត្រា២៥) សិទ្ធិបោះឆ្នោត និងឈរឈ្មោះបោះឆ្នោត (មាត្រា២៩)។ ប្រសិនបើគ្មានការទទួលស្គាល់បុគ្គលនោះ ថាជាមនុស្សនៅចំពោះមុខច្បាប់ទេ សមត្ថភាពក្នុងការទាមទារការអនុវត្ត និងការដាក់ឲ្យប្រតិបត្តិសិទ្ធិទាំងនោះ និងសិទ្ធិដទៃផ្សេងទៀតក្នុងអនុសញ្ញានេះ នឹងធ្វើឲ្យអន្តរាយយ៉ាងខ្លាំង។

## មាត្រា៨៖ សមតាព និងការមិនរើសអើង

៣២. ដើម្បីសម្រេចបានការទទួលស្គាល់ ដោយស្មើភាពគ្នា នៅចំពោះមុខច្បាប់ សមត្ថភាពខាងផ្នែកច្បាប់មិនត្រូវបានគេបដិសេធ ដោយរើសអើងជាដាច់ខាត។ មាត្រា៥ នៃអនុសញ្ញា ធានាឲ្យមានសមភាពសម្រាប់ពលរដ្ឋទាំងអស់នៅក្រោមច្បាប់ និងនៅចំពោះមុខច្បាប់ ព្រមទាំងសិទ្ធិក្នុងការទទួលបានការការពារ ដោយស្មើភាពគ្នាតាមផ្លូវច្បាប់។ បទប្បញ្ញត្តិនេះ ហាមឃាត់យ៉ាងច្បាស់រាល់ការរើសអើងទាំងអស់ ដោយឈរលើមូលដ្ឋាននៃពិការភាព។ ការរើសអើងដោយឈរលើមូលដ្ឋាននៃពិការភាពត្រូវបានកំណត់យ៉ាងច្បាស់ក្នុងមាត្រា២ នៃអនុសញ្ញាថា ជា "ការបែងចែក ការផាត់ចេញ ឬការដាក់កំហិតណាមួយ ដោយសារតែពិការភាព ដែលមានបំណង ឬមានអានុភាពធ្វើឲ្យចុះទន់ខ្សោយ ឬគ្មានការទទួលស្គាល់ការអនុវត្ត ឬការទទួលបាននូវសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្តទាំងអស់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ"។ ការបដិសេធសមត្ថភាពខាងផ្នែកច្បាប់ដែលមានគោលបំណង ឬអនុភាពជ្រៀតជ្រែកដល់សិទ្ធិជនពិការ ក្នុងការទទួលបានការទទួលស្គាល់ដោយស្មើភាពគ្នានៅចំពោះមុខច្បាប់គឺជាការរំលោភបំពានលើមាត្រា៥ និង១២ នៃអនុសញ្ញា។ តាមពិតទៅ រដ្ឋមួយមានសមត្ថភាពក្នុងការរឹតត្បិតសមត្ថភាពខាងផ្នែកច្បាប់របស់បុគ្គលណាម្នាក់បាន ដោយផ្អែកទៅលើកាលៈទេសៈជាក់ស្តែងមួយចំនួន ដូចជា ការក្ស័យធន ឬការផ្តន្ទាទោសព្រហ្មទណ្ឌ។ ក៏ប៉ុន្តែ សិទ្ធិទទួលបានការទទួលស្គាល់ដោយស្មើភាពគ្នានៅចំពោះមុខច្បាប់ និងសេរីភាពរួចផុតពីការរើសអើង ទាមទារថា នៅពេល

ដែលរដ្ឋបដិសេធសមត្ថភាពខាងផ្នែកច្បាប់នោះ រដ្ឋត្រូវធ្វើឡើង ដោយឈរលើមូលដ្ឋានដូចគ្នា សម្រាប់បុគ្គលទាំងអស់គ្នា។ ការបដិសេធសមត្ថភាពខាងផ្នែកច្បាប់មិនត្រូវផ្អែកទៅលើលក្ខណៈរបស់បុគ្គល ដូចជាយេនឌ័រ ពូជសាសន៍ ឬពិការភាព ឬ ដោយមានគោលបំណង ឬមានអនុភាពក្នុងការប្រព្រឹត្តទៅលើបុគ្គលទាំងនោះ ផ្សេងពីការប្រព្រឹត្តទៅលើអ្នកដទៃផ្សេងៗទៀតនោះទេ។

**៣៣.** សេរីភាពរួចផុតពីការរើសអើង ក្នុងការទទួលស្គាល់សមត្ថភាពខាងផ្នែកច្បាប់ជាការស្តារស្វ័យភាព និងការគោរពសេចក្តីថ្លៃថ្នូររបស់បុគ្គលក្នុងនាមជាមនុស្ស ដោយអនុលោមតាមគោលការណ៍ទាំងឡាយដែលមានចែងក្នុងមាត្រា៣(ក) នៃអនុសញ្ញា។ សេរីភាពក្នុងការជ្រើសរើសដោយខ្លួនឯងញឹកញាប់បំផុតត្រូវការសមត្ថភាពខាងផ្នែកច្បាប់។ ឯករាជភាព និងស្វ័យភាព រាប់បញ្ចូលទាំងអំណាចទទួលបានការគោរពតាមផ្លូវច្បាប់ ទៅលើការសម្រេចចិត្តរបស់បុគ្គលណាម្នាក់នោះទៀតផង។ តម្រូវការឲ្យមានការគាំទ្រ និងការផ្តល់ដំណោះស្រាយសមហេតុផល ក្នុងការធ្វើសេចក្តីសម្រេចចិត្ត នឹងមិនត្រូវបានគេយកទៅប្រើប្រាស់ក្នុងការដេញដោលលើសមត្ថភាពខាងផ្នែកច្បាប់របស់បុគ្គលនោះទេ។ ការគោរព និងការទទួលស្គាល់ជនពិការប្រភេទខុសៗគ្នា ជាផ្នែកមួយនៃភាពចម្រុះរបស់មនុស្ស និងមនុស្សជាតិ (មាត្រា៣(ឃ)) គឺមានវិសមិតភាពជាមួយនឹងការផ្តល់សមត្ថភាពខាងផ្នែកច្បាប់ដោយឈរលើមូលដ្ឋាននៃការអនុវត្តឲ្យដូចគ្នា (គំនិតធ្វើឲ្យដូចគ្នានោះទេ)។

៣៤. ការមិនរើសអើង រាប់បញ្ចូលទាំងសិទ្ធិទទួលបាននូវដំណោះស្រាយសមហេតុផលនៅក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់ (មាត្រា ៥ កថាខណ្ឌ៣)។ ដំណោះស្រាយសមហេតុផល ត្រូវបានកំណត់យ៉ាងច្បាស់ នៅក្នុងមាត្រា២ នៃអនុសញ្ញាថាជា "ការកែប្រែ និងការកែតម្រូវដែលសមរម្យ និងចាំបាច់ ដោយការមិនដាក់បន្ទុកដែលអសមាមាត្រ ឬហួសហេតុ ដែលគេត្រូវការចាំបាច់ក្នុងករណីពិសេស ដើម្បីធានាដល់ជនពិការក្នុងការទទួលបាន និងអនុវត្តសិទ្ធិនិងសេរីភាពជាមូលដ្ឋានទាំងអស់ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយនឹងអ្នកដទៃ"។ សិទ្ធិក្នុងការទទួលបាននូវដំណោះស្រាយសមហេតុផល ក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់ មានភាពដាច់ចេញពី និងបំពេញបន្ថែមទៅលើសិទ្ធិក្នុងការទទួលបានការគាំទ្រ ក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់។ រដ្ឋភាគីតម្រូវឲ្យធ្វើការកែប្រែ ឬការកែតម្រូវនានា ដើម្បីឲ្យជនពិការអាចប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់របស់ខ្លួនបាន លុះត្រាតែវាមានអសមាមាត្រ ឬជាបន្ទុកហួសហេតុ។ ការកែប្រែ ឬការតម្រូវបែបនោះ អាចរាប់បញ្ចូលទាំងការប្រើប្រាស់អាគារសំខាន់ៗ ជារួម មានដូចជា តុលាការ ធនាគារ ការិយាល័យ ផលប្រយោជន៍សង្គម និងការិយាល័យបោះឆ្នោត ការទទួលបានព័ត៌មានពាក់ព័ន្ធនឹងសេចក្តីសម្រេចផ្សេងៗ ដែលមានអនុភាពផ្លូវច្បាប់ និងជំនួយផ្ទាល់តែមិនរឹតត្បឹត ចំពោះសិទ្ធិទាំងអស់នេះទេ។ សិទ្ធិក្នុងការទទួលបានការគាំទ្រ ដើម្បីប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់មិនត្រូវបានរឹតត្បឹតដោយសារការទាមទារដែលមានលក្ខណៈអសមាមាត្រ និងជាបន្ទុកហួសហេតុ។ រដ្ឋមានកាតព្វកិច្ចដាច់ខាត ក្នុងការផ្តល់ឲ្យមានការទទួលបានការគាំទ្រ ដើម្បីប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់នេះ។

## មាត្រា៦៖ ស្ត្រីពិការ

៣៥. មាត្រា១៥ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ ចែងអំពីសមត្ថភាពខាងផ្នែកច្បាប់របស់ស្ត្រីដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយបុរស ដោយហេតុនោះ មានការទទួលស្គាល់ថា ការទទួលស្គាល់សមត្ថភាពខាងផ្នែកច្បាប់ គឺជាចំណុចស្នូលចំពោះការទទួលបានការទទួលស្គាល់ ដោយស្មើភាពគ្នានៅចំពោះមុខច្បាប់។ មាត្រានេះចែងថា "រដ្ឋភាគីត្រូវផ្តល់ឲ្យស្ត្រីនូវសមត្ថភាពខាងផ្នែកច្បាប់ឲ្យដូចគ្នានឹងបុរសក្នុងរឿងរដ្ឋប្បវេណី និងមានឱកាសដូចគ្នាក្នុងការប្រើប្រាស់សមត្ថភាពនេះ។ ជាពិសេស រដ្ឋភាគីត្រូវផ្តល់ឲ្យស្ត្រីនូវសិទ្ធិស្មើគ្នាក្នុងការចុះកិច្ចសន្យា និងការគ្រប់គ្រងទ្រព្យ និងត្រូវប្រព្រឹត្តមកលើស្ត្រីដូចគ្នាក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការ និងសាលាជម្រះក្តី" (កថាខណ្ឌ២)។ បទប្បញ្ញត្តិនេះត្រូវអនុវត្តទៅលើស្ត្រីទាំងអស់ ដោយរាប់ទាំងស្ត្រីពិការដែរ។ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការទទួលស្គាល់ថាស្ត្រីពិការអាចទទួលរងនូវការរើសអើងច្រើនទម្រង់ និងអន្តរវិស័យ ដោយសារតែយេនឌ័រ និងពិការភាព។ ឧទាហរណ៍ ស្ត្រីពិការទទួលរងការគៀរដោយបង្ខំក្នុងអាត្រាមួយយ៉ាងខ្ពស់ ហើយច្រើនតែគេបដិសេធមិនឲ្យទទួលបានការគ្រប់គ្រងទៅលើសុខភាពបន្តពូជ និងការសម្រេចចិត្តរបស់ខ្លួននោះទេ សន្និដ្ឋានថា ស្ត្រីពិការទាំងនោះមិនមានសមត្ថភាពក្នុងការយល់ព្រមទៅលើបញ្ហារួមភេទទេ។ យុត្តាធិការជាក់លាក់មួយចំនួន ក៏បានដាក់អ្នកសម្រេចចិត្តជំនួសសម្រាប់ស្ត្រីក្នុងអាត្រាច្រើនជាងដាក់អ្នកសម្រេចចិត្តជំនួសសម្រាប់បុរស។ ដូច្នេះ វាជាប្រការសំខាន់យ៉ាងពិសេស ក្នុងការបញ្ជាក់ឲ្យច្បាស់សារជាថ្មីថា សមត្ថភាពខាងផ្នែកច្បាប់របស់ស្ត្រីពិការ គួរត្រូវបានទទួលស្គាល់ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។

## មាត្រា៧៖ កុមារពិការ

**៣៦.** ខណៈដែលមាត្រា១២ នៃអនុសញ្ញានេះការពារភាពស្មើគ្នានៅចំពោះមុខច្បាប់សម្រាប់បុគ្គលទាំងអស់ ដោយមិនគិតពីអាយុនោះ មាត្រា៧ នៃអនុសញ្ញាទទួលស្គាល់ការអភិវឌ្ឍសមត្ថភាពរបស់កុមារ និងតម្រូវថា "នៅគ្រប់សកម្មភាពទាំងអស់ដែលទាក់ទងនឹងកុមារពិការ ឧត្តមប្រយោជន៍របស់កុមារពិការ [...] លើកយកមកពិចារណាមុនគេ" (កថាខណ្ឌ២) និងថា "ទស្សនៈរបស់ពួកគេត្រូវទទួលបានការពិចារណាថ្លឹងថ្លែងឲ្យបានសមស្របទៅនឹងអាយុ និងភាពចាស់ទុំរបស់ពួកគេ" (កថាខណ្ឌ៣)។ ដើម្បីអនុវត្តតាមមាត្រា១២ រដ្ឋភាគីត្រូវតែពិនិត្យលើច្បាប់ទាំងឡាយរបស់ខ្លួនដើម្បីធានាថា ឆន្ទៈ និងចំណង់ចំណូលចិត្តរបស់កុមារពិការទទួលបានការគោរព ដោយឈរលើមូលដ្ឋាននៃភាពស្មើគ្នាជាមួយកុមារដទៃទៀត។

## មាត្រា៩៖ ការបង្កលក្ខណៈងាយស្រួល

**៣៧.** សិទ្ធិនានាដែលមានចែងក្នុងមាត្រា១២ មានចំណងយ៉ាងជិតស្និទ្ធជាមួយនឹងកាតព្វកិច្ចរបស់រដ្ឋ ពាក់ព័ន្ធនឹងការបង្កលក្ខណៈងាយស្រួល (មាត្រា៩) ពីព្រោះថា ការទទួលស្គាល់ស្មើភាពគ្នានៅចំពោះមុខច្បាប់មានភាពចាំបាច់ក្នុងការធ្វើឲ្យជនពិការរស់នៅដោយឯករាជ្យ និងចូលរួមពេញលេញក្នុងគ្រប់ទិដ្ឋភាពនៃជីវិត។ មាត្រា៩ ទាមទារឲ្យមានការកំណត់នូវអត្តសញ្ញាណកម្ម និងការលុបបំបាត់ឧបសគ្គនានាដែលមានចំពោះគ្រឿងសំរួល ឬសេវាកម្មបើកចំហរ ឬដែលផ្តល់ដល់សាធារណជនទូទៅ។ កង្វះការបង្កលក្ខណៈងាយស្រួលផ្នែកព័ត៌មាន និងទំនាក់ទំនង ព្រមទាំងសេវាកម្មដែលមិនបង្កលក្ខណៈងាយស្រួល អាចបង្កើតជាឧបសគ្គ

ក្នុងការសម្រេចបានសមត្ថភាពខាងផ្នែកច្បាប់ សម្រាប់ជនពិការមួយចំនួន ក្នុងស្ថានភាពនៃការអនុវត្តជាក់ស្តែង។ ដូច្នេះ រដ្ឋភាគីត្រូវតែតាក់តែងនីតិវិធីទាំងអស់នេះ សម្រាប់ការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់ និងប្រើប្រាស់ព័ត៌មាន និងទំនាក់ទំនងទាំងអស់ដែលទាក់ទងនឹងបង្កលក្ខណៈងាយស្រួលពេញលេញ។ រដ្ឋភាគីត្រូវតែពិនិត្យឡើងវិញទៅលើច្បាប់ និងការអនុវត្តរបស់ខ្លួន ដើម្បីធានាថា សិទ្ធិទទួលបានសមត្ថភាពខាងផ្នែកច្បាប់ និងការបង្កលក្ខណៈងាយស្រួល ត្រូវសម្រេចឲ្យបាន។

## មាត្រា១៣៖ សិទ្ធិទទួលបានយុត្តិធម៌

៣៨. រដ្ឋភាគីមានកាតព្វកិច្ចមួយ ក្នុងការធានាថាជនពិការមានសិទ្ធិទទួលបានយុត្តិធម៌ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។ ការទទួលស្គាល់សិទ្ធិក្នុងការទទួលបានសមត្ថភាពខាងផ្នែកច្បាប់ មានសារៈសំខាន់ចំពោះសិទ្ធិទទួលបានយុត្តិធម៌ក្នុងទិដ្ឋភាពជាច្រើន។ ដើម្បីស្វែងរកការប្រតិបត្តិសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ជនពិការត្រូវតែទទួលបានការទទួលស្គាល់ជាបុគ្គល នៅចំពោះមុខច្បាប់ ដោយមានឋានៈស្មើគ្នា នៅក្នុងតុលាការ និងសាលាជម្រះក្តីផ្សេងៗ។ រដ្ឋភាគីក៏ត្រូវតែធានាផងដែរថា ជនពិការមានសិទ្ធិទទួលបានតំណាងផ្នែកច្បាប់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។ នេះត្រូវរកឃើញថាជាបញ្ហាមួយក្នុងយុត្តាធិការជាច្រើន ហើយត្រូវតែមានដំណោះស្រាយ ដោយរាប់បញ្ចូលទាំងតាមរយៈការធានាថា បុគ្គលដែលទទួលរងការរារាំងរំខានក្នុងការទទួលបានសិទ្ធិមានសមត្ថភាពខាងផ្នែកច្បាប់ មានឱកាសក្នុងការតបតជំទាស់ទៅនឹងការរារាំងរំខាន

បែបនេះ (ដោយខ្លួនឯង ឬដោយតំណាងផ្នែកច្បាប់) ព្រមទាំងដើម្បីការពារសិទ្ធិរបស់ពួកគេក្នុងតុលាការ។ ជនពិការច្រើនតែត្រូវបានគេផាត់ចេញពីតួនាទីសំខាន់ៗ នៅក្នុងប្រព័ន្ធយុត្តិធម៌ ដូចជា មេធាវី ចៅក្រម សាក្សី ឬសមាជិកគណៈវិនិច្ឆ័យ។

៣៩. មន្ត្រីប៉ូលីស អ្នកបំរើការងារសង្គមកិច្ច និងអ្នកឆ្លើយតបដំបូងដទៃទៀត ត្រូវតែទទួលការបណ្តុះបណ្តាលក្នុងការទទួលស្គាល់ជនពិការជាបុគ្គលពេញលេញនៅចំពោះមុខច្បាប់ និងផ្តល់ឲ្យការថ្លឹងថ្លែងដូចគ្នាទៅលើបណ្តឹង និងការលើកឡើងរបស់ជនពិការដូចដែលគេផ្តល់ឲ្យដល់ជនមិនពិការដែរ។ ប្រការនេះតម្រូវឲ្យមានការការបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងនៅក្នុងវិជ្ជាជីវៈដែលមានសារសំខាន់ទាំងនេះ។ គេត្រូវតែផ្តល់ដល់ជនពិការនូវសមត្ថភាពខាងផ្នែកច្បាប់ដើម្បីផ្តល់សក្ខីកម្ម ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។ មាត្រា១២ នៃអនុសញ្ញាធានាឲ្យមានការគាំទ្រក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់ រួមទាំងសមត្ថភាពក្នុងការផ្តល់សក្ខីកម្មក្នុងដំណើរការនីតិវិធីតុលាការ រដ្ឋបាល និងផ្លូវច្បាប់ផ្សេងទៀត។ ការគាំទ្របែបនេះ អាចមានជាទម្រង់ផ្សេងៗគ្នាដោយរាប់បញ្ចូលទាំងការទទួលស្គាល់មធ្យោបាយទំនាក់ទំនងផ្សេងៗគ្នាតាមរយៈការអនុញ្ញាតិឲ្យមានការផ្តល់សក្ខីកម្ម តាមវីដេអូក្នុងស្ថានភាពមួយចំនួន ការផ្តល់ដំណោះស្រាយផ្នែកនីតិវិធី ការផ្តល់ការបកប្រែភាសាសញ្ញាដែលមានលក្ខណៈវិជ្ជាជីវៈ និងវិធីសាស្ត្រជំនួយផ្សេងៗទៀត។ ផ្នែកតុលាការត្រូវតែទទួលបានការបណ្តុះបណ្តាល និងត្រូវតែមានការយល់ដឹងអំពីកាតព្វកិច្ចរបស់គេ ក្នុងការគោរពសមត្ថភាពខាងផ្នែកច្បាប់របស់ជនពិការ ដោយគិតទាំងទីភ្នាក់ងារខាងផ្នែកច្បាប់ និងឋានៈផ្លូវច្បាប់។

## មាត្រា១៤ និងមាត្រា២៥៖ សេរីភាព សន្តិសុខ និងការយល់ព្រម

៤០. ការគោរពសិទ្ធិទទួលបានសមត្ថភាពខាងផ្នែកច្បាប់របស់ជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ រួមមានការគោរពសិទ្ធិជនពិការក្នុងការទទួលបានសេរីភាព និងសន្តិសុខបុគ្គល។ ការបដិសេធសមត្ថភាពខាងផ្នែកច្បាប់របស់ជនពិការ និងការឃុំខ្លួនពួកគេក្នុងស្ថាប័ននានាដែលផ្ទុយនឹងឆន្ទៈរបស់ពួកគេ ទាំងមិនមានការយល់ព្រមពីខ្លួនគេ ឬមិនមានការយល់ព្រមពីអ្នកសម្រេចចិត្តជំនួសគេក៏ដោយ គឺជាបញ្ហាដែលកំពុងបន្តកើតមាន។ ការអនុវត្តបែបនេះបង្កើតបានជាការដកហូតសេរីភាពតាមទំនើងចិត្ត និងបំពានលើមាត្រា១២ និងមាត្រា១៤ នៃអនុសញ្ញានេះ។ រដ្ឋភាគីត្រូវតែរារាំងមិនឲ្យមានការអនុវត្តបែបនេះ និងត្រូវតែបង្កើតយន្តការមួយដើម្បីពិនិត្យមើលឡើងវិញ ទៅលើករណីនានាដែលនៅក្នុងនោះ ជនពិការត្រូវបានដាក់ឲ្យស្ថិតនៅក្នុងទីស្នាក់អាស្រ័យណាមួយ ដោយមិនមានការយល់ព្រមជាក់លាក់ពីពួកគេ។

៤១. សិទ្ធិទទួលបាននូវបទដ្ឋានសុខភាពខ្ពស់បំផុត (មាត្រា២៥) រាប់បញ្ចូលទាំងសិទ្ធិទទួលបានការថែទាំសុខភាពដោយឈរលើមូលដ្ឋាននៃការយល់ព្រមដោយសេរី និងផ្តល់ព័ត៌មានឲ្យដឹង។ រដ្ឋភាគីមានកាតព្វកិច្ចក្នុងការតម្រូវឲ្យអ្នកវិជ្ជាជីវៈសុខាភិបាល និងវេជ្ជសាស្ត្រ (ដោយរាប់ទាំងអ្នកវិជ្ជាជីវៈវិកលវិទ្យាផង) ក្នុងការទទួលការយល់ព្រមដោយសេរី និងផ្តល់ព័ត៌មានឲ្យដឹងពីជនពិការមុនពេលព្យាបាលណាមួយ។ ចំពោះសិទ្ធិទទួលបានសមត្ថភាពខាងផ្នែកច្បាប់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នា

ជាមួយអ្នកដទៃ រដ្ឋភាគីមានកាតព្វកិច្ចក្នុងការមិនអនុញ្ញាតឲ្យអ្នកសម្រេចចិត្តជំនួស ក្នុងការផ្តល់ការយល់ព្រមជំនួសឲ្យជនពិការឡើយ។ បុគ្គលិកសុខាភិបាល និងវេជ្ជសាស្ត្រទាំងអស់ គួរធានាឲ្យមានការពិគ្រោះយោបល់សមស្របដែលមានការចូលរួមដោយផ្ទាល់ពីជនពិការ។ ពួកគេក៏គួរធានាឲ្យអស់លទ្ធភាពថា ជំនួយការ ឬអ្នកផ្តល់ការគាំទ្រ មិនជំនួស ឬមិនមានឥទ្ធិពលហួសហេតុទៅលើការសម្រេចចិត្តរបស់ជនពិការឡើយ។

## មាត្រា១៥ មាត្រា១៦ និងមាត្រា១៧៖ ការគោរពសុចរិតភាពបុគ្គល និងសេរីភាពរួចផុតពីអំពើទារុណកម្ម អំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពាន

៤២. ដូចមានបញ្ជាក់ក្នុងសេចក្តីសង្កេតសន្និដ្ឋានជាច្រើនរួចមកហើយ ការព្យាបាលដោយបង្ខំពីពេទ្យវិកលចរិក និងអ្នកវិជ្ជាជីវៈសុខាភិបាល និងវេជ្ជសាស្ត្រដទៃទៀត គឺជាការរំលោភបំពានទៅលើសិទ្ធិក្នុងការទទួលបានការទទួលស្គាល់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នានៅចំពោះមុខច្បាប់ និងជាការបំពានទៅលើសិទ្ធិទទួលបានសុចរិតភាពបុគ្គល (មាត្រា១៧) សេរីភាពរួចផុតពីអំពើទារុណកម្ម (មាត្រា១៥) និងសេរីភាពរួចផុតពីអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពាន(មាត្រា១៦)។ ការអនុវត្តនេះ ជាការបដិសេធសមត្ថភាពខាងផ្នែកច្បាប់របស់បុគ្គល ក្នុងការជ្រើសរើសការព្យាបាលវេជ្ជសាស្ត្រ ហេតុដូច្នេះ វាជាការរំលោភទៅលើមាត្រា១២ នៃអនុសញ្ញា។ ផ្ទុយមកវិញ រដ្ឋភាគីត្រូវតែគោរពសមត្ថ

ភាពខាងផ្នែកច្បាប់របស់ជនពិការក្នុងការធ្វើការសម្រេចចិត្តនៅគ្រប់ពេលវេលា ដោយរាប់បញ្ចូលទាំងក្នុងស្ថានភាពមានវិបត្តិផង ត្រូវតែធានាថាមានការផ្តល់ព័ត៌មានសុក្រឹត្យ និងបង្កលក្ខណៈងាយស្រួល អំពីជម្រើសសេវាកម្ម និងធានាថា វិធីសាស្រ្តមិនមែនតាមបែបវេជ្ជសាស្រ្តក៏អាចរកបានដែរ ព្រមទាំងផ្តល់ការគាំទ្រដោយឯករាជ្យ។ រដ្ឋភាគីមានកាតព្វកិច្ចមួយក្នុងការផ្តល់ការគាំទ្រ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ពាក់ព័ន្ធនឹងការព្យាបាលបែបវិកលវិទ្យា និងបែបវេជ្ជសាស្រ្តផ្សេងៗទៀត។ ការព្យាបាលដោយបង្ខំ គឺជាបញ្ហាពិសេសមួយសម្រាប់ជនពិការផ្នែកចិត្តសង្គម ផ្នែកបញ្ញា និងផ្នែកគំនិតផ្សេងៗទៀត។ រដ្ឋភាគីត្រូវតែលុបបំបាត់ចោលឲ្យអស់នូវគោលនយោបាយ និងបទប្បញ្ញត្តិច្បាប់ទាំងឡាយណាដែលអនុញ្ញាតិ ឬប្រព្រឹត្តក្នុងការព្យាបាលដោយបង្ខំ ដោយសារតែវាជាការរំលោភបំពានមិនឈប់ឈរ ដែលគេរកឃើញមាននៅក្នុងច្បាប់ស្តីពីសុខភាពផ្លូវចិត្តនានាជុំវិញពិភពលោក ទោះបីជាមានភស្តុតាងជាក់ស្តែង បង្ហាញអំពីកង្វះប្រសិទ្ធភាព និងអំពីទស្សនៈផ្សេងៗរបស់មនុស្ស ដែលប្រើប្រាស់ប្រព័ន្ធសុខភាពផ្លូវចិត្តដែលធ្លាប់ទទួលរងការឈឺចាប់យ៉ាងខ្លាំង និងទទួលរងការប៉ះទង្គិចផ្លូវចិត្ត ដោយសារតែការព្យាបាលដោយបង្ខំនេះក៏ដោយ។ គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីធានាថា ការសម្រេចចិត្តពាក់ព័ន្ធនឹងសុចរិតភាពរាងកាយ ឬផ្លូវចិត្តរបស់បុគ្គលអាចធ្វើឡើងបាន លុះត្រាតែមានការយល់ព្រមដោយសេរី និងផ្តល់ព័ត៌មានឲ្យដឹងពីបុគ្គលពាក់ព័ន្ធ។

## មាត្រា១៨៖ សញ្ជាតិ

៤៣. ជនពិការមានសិទ្ធិទទួលបានឈ្មោះមួយ និងទទួលបានការចុះបញ្ជីកំណើត ជាផ្នែកមួយនៃសិទ្ធិទទួលបានការទទួលស្គាល់គ្រប់ទីកន្លែង ជាបុគ្គលនៅចំពោះមុខច្បាប់ (មាត្រា១៨ កថាខណ្ឌ២)។ រដ្ឋភាគីត្រូវតែចាត់វិធានការចាំបាច់ក្នុងការធានាថា កុមារពិការបានទទួលការចុះបញ្ជីបន្ទាប់ពីប្រសូតមកភ្លាម។ សិទ្ធិនេះមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ(មាត្រា៧) ក៏ប៉ុន្តែ កុមារពិការទំនងជាមិនបានចុះបញ្ជីដោយអសមាមាត្រ បើប្រៀបធៀបនឹងកុមារដទៃទៀត។ នេះជាការបដិសេធពួកគេពីភាពជាពលរដ្ឋ ហើយក៏ច្រើនតែបដិសេធពួកគេមិនឲ្យទទួលបានសេវាថែទាំសុខភាព និងអប់រំ ហើយថែមទាំងអាចបណ្តាលឲ្យស្លាប់ផងក៏មានដែរ។ ដោយសារតែមិនមានកំណត់ត្រាជាផ្លូវការអំពីអត្ថិភាពនេះ ធ្វើឲ្យការស្លាប់របស់កុមារ អាចកើតឡើងបាន គ្មានអ្នកទទួលទោសពៃរ៍អ្វីឡើយ។

## មាត្រា១៩៖ ការរស់នៅដោយឯករាជ្យ និងបញ្ចូលក្នុងសហគមន៍

៤៤. ដើម្បីសម្រេចបានសិទ្ធិនានា ដែលមានចែងក្នុងមាត្រា១២ វាជាការសំខាន់ណាស់ដែលជនពិការត្រូវមានឱកាសក្នុងការអភិវឌ្ឍ និងបង្ហាញឆន្ទៈ និងចំណង់ចំណូលចិត្តរបស់ខ្លួន ក្នុងគោលបំណង ដើម្បីប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។ នេះមានន័យថា ជនពិការត្រូវតែមានឱកាសរស់នៅដោយឯករាជ្យក្នុងសហគមន៍ និងមានឱកាសជ្រើសរើស និងត្រួតត្រាទៅលើជីវិតប្រចាំថ្ងៃរបស់ពួកគេ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃដូចមានចែងក្នុងមាត្រា១៩។

៤៥. ការបកស្រាយមាត្រា១២ កថាខណ្ឌ៣ ពាក់ព័ន្ធនឹងសិទ្ធិរស់នៅក្នុងសហគមន៍(មាត្រា១៩) មានន័យថាការគាំទ្រក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់ គួរផ្តល់ឲ្យដោយប្រើប្រាស់វិធីសាស្រ្តផ្អែកលើសហគមន៍។ រដ្ឋភាគីត្រូវតែទទួលស្គាល់ថា សហគមន៍គឺជាទ្រព្យ និងជាដៃគូក្នុងដំណើរការកំណត់អំពីប្រភេទនៃការគាំទ្រ ដែលគេត្រូវការក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់ ដោយរាប់បញ្ចូលទាំងការលើកកម្ពស់ការយល់ដឹងអំពីជម្រើសគាំទ្រផ្សេងៗគ្នា។ រដ្ឋភាគីត្រូវតែទទួលស្គាល់បណ្តាញសង្គម និងការគាំទ្ររបស់សហគមន៍ដែលកើតឡើងដោយឯកឯង (ដោយរាប់បញ្ចូលទាំងមិត្តភក្តិ គ្រួសារ និងសាលារៀន) របស់ជនពិការជាកត្តាសំខាន់ចំពោះការធ្វើសេចក្តីសម្រេចចិត្តដែលមានផ្តល់កិច្ចគាំទ្រ។ ប្រការនេះ ស៊ីសង្វាក់ទៅនឹងការគូសបញ្ជាក់នៃអនុសញ្ញាពាក់ព័ន្ធនឹងការដាក់បញ្ចូល និងការចូលរួមពេញលេញរបស់ជនពិការក្នុងសហគមន៍។

៤៦. ការដាក់ជនពិការដាច់ដោយឡែកក្នុងស្ថាប័ននានា នៅតែបន្តកើតឡើងជាបញ្ហារីករាលដាល និងគួរឲ្យខ្លាច ដែលជាការរំលោភទៅលើសិទ្ធិមួយចំនួនដែលមានធានានៅក្នុងអនុសញ្ញា។ បញ្ហានេះកាន់តែមានសភាពធ្ងន់ធ្ងរឡើង ដោយសារតែការបដិសេធកាន់តែរីករាលដាលនូវសមត្ថភាពខាងផ្នែកច្បាប់របស់ជនពិការជាទូទៅនេះ ដែលអនុញ្ញាតិឲ្យអ្នកដទៃយល់ព្រមក្នុងការដាក់ពួកគេ នៅក្នុងមជ្ឈដ្ឋានស្ថាប័នណាមួយនោះ។ ជាទូទៅ ប្រធានស្ថាប័នទាំងនោះ ក៏ត្រូវបានគេផ្តល់ឲ្យនូវសមត្ថភាពខាងផ្នែកច្បាប់របស់ជនពិការដែលស្នាក់នៅក្នុងនោះដែរ។ អំណាច និងការត្រួតត្រាគ្រប់បែបយ៉ាងទៅលើបុគ្គល គឺស្ថិតនៅក្នុងដៃស្ថាប័ននៅ

ក្នុងកន្លែងទាំងនោះ។ ដើម្បីអនុវត្តតាមអនុសញ្ញា និងគោរពសិទ្ធិមនុស្ស របស់ជនពិការ គេត្រូវតែបញ្ឈប់ការធ្វើស្ថាប័ននីយកម្មនេះឲ្យបាន ហើយត្រូវតែស្តារសមត្ថភាពខាងផ្នែកច្បាប់នេះ ដល់ជនពិការទាំងអស់ ដែលត្រូវតែមានលទ្ធភាពក្នុងការជ្រើសរើសកន្លែងរស់នៅ និងមនុស្សដែលពួកគេរស់នៅជាមួយ (មាត្រា១៩)។ ជម្រើសរបស់បុគ្គលម្នាក់អំពីកន្លែងរស់នៅ និងមនុស្សរស់នៅជាមួយមិនគួរប៉ះពាល់ដល់សិទ្ធិរបស់ពួកគាត់ ក្នុងការទទួលបានការគាំទ្រ ដើម្បីប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់របស់ពួកគាត់ឡើយ។

## មាត្រា២២៖ សិទ្ធិឯកជន

៤៧. ក្រៅពីមិនស្របទៅនឹងមាត្រា១២ នៃអនុសញ្ញា របបធ្វើការសម្រេចចិត្តជំនួសនេះ ក៏អាចរំលោភយ៉ាងមានសក្តានុពល ទៅលើសិទ្ធិឯកជនរបស់ជនពិការដែរ ដោយសារថា អ្នកធ្វើសេចក្តីសម្រេចចិត្តជំនួសជាធម្មតា ទទួលបានការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានផ្សេងៗទៀតជាច្រើនពាក់ព័ន្ធនឹងបុគ្គលនោះ។ ក្នុងការបង្កើតឲ្យមានប្រព័ន្ធធ្វើការសម្រេចចិត្តដោយមានការគាំទ្រនេះ រដ្ឋភាគីត្រូវតែធានាថា អ្នកដែលផ្តល់ការជួយគាំទ្រក្នុងការប្រើប្រាស់សមត្ថភាពផ្លូវច្បាប់ ត្រូវគោរពសិទ្ធិឯកជនរបស់ជនពិការឲ្យបានពេញលេញ។

## មាត្រា២៩៖ ការចូលរួមក្នុងជីវភាពនយោបាយ

៤៨. ការបដិសេធ ឬការរឹតត្បឹតសមត្ថភាពខាងផ្នែកច្បាប់ត្រូវបានគេប្រើប្រាស់ដើម្បីបដិសេធការចូលរួមក្នុងជីវភាពនយោបាយ ជាពិសេស

សិទ្ធិបោះឆ្នោតសម្រាប់ជនពិការពិតប្រាកដមួយចំនួន។ ដើម្បីសម្រេចបានការទទួលស្គាល់ដោយស្មើភាពគ្នាចំពោះសមត្ថភាពខាងផ្នែកច្បាប់ឲ្យបានពេញលេញនៅក្នុងគ្រប់ទិដ្ឋភាពនៃជីវិត វាជាការសំខាន់ណាស់ក្នុងការទទួលស្គាល់សមត្ថភាពខាងផ្នែកច្បាប់ឲ្យបានពេញលេញ នៅក្នុងគ្រប់ទិដ្ឋភាពនៃជីវិត វាជាការសំខាន់ណាស់ក្នុងការទទួលស្គាល់សមត្ថភាពខាងផ្នែកច្បាប់របស់ជនពិការ ក្នុងជីវភាពសាធារណៈ និងជីវភាពនយោបាយ (មាត្រា២៩)។ នេះមានន័យថា សមត្ថភាពធ្វើការសម្រេចចិត្តរបស់បុគ្គលម្នាក់ មិនអាចយកទៅប្រើជាយុត្តិកម្មសម្រាប់ការផាត់ចេញជនពិការក្នុងការអនុវត្តសិទ្ធិនយោបាយរបស់ខ្លួនបានទេ ដោយរាប់ទាំងសិទ្ធិបោះឆ្នោតសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត និងសិទ្ធិធ្វើជាសមាជិកគណៈវិនិច្ឆ័យដែរ។

៤៩. រដ្ឋភាគីមានកាតព្វកិច្ចមួយ ក្នុងការការពារ និងលើកកម្ពស់សិទ្ធិជនពិការ ក្នុងការទទួលបានការគាំទ្រតាមជម្រើសរបស់គេ ក្នុងការបោះឆ្នោតតាមរយៈសន្លឹកឆ្នោតសម្ងាត់ និងដើម្បីចូលរួមនៅគ្រប់ការបោះឆ្នោត និងរាល់ការធ្វើប្រជាមតិដោយគ្មានការរើសអើង។ គណៈកម្មាធិការផ្តល់អនុសាសន៍បន្ថែមថា រដ្ឋភាគីត្រូវធានាឲ្យមានសិទ្ធិរបស់ជនពិការក្នុងការឈរឈ្មោះបោះឆ្នោត ក្នុងការកាន់កាប់តួនាទីដោយប្រសិទ្ធភាព និងក្នុងការបំពេញមុខងារសាធារណៈ នៅគ្រប់កម្រិតទាំងអស់របស់រដ្ឋាភិបាល ដោយមានដំណោះស្រាយ និងការគាំទ្រសមហេតុផលក្នុងករណីណាដែលមានសេចក្តីប្រាថ្នាក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់របស់ពួកគេ។

## V. ការអនុវត្តនៅថ្នាក់ជាតិ

៥០. ក្នុងក្របខ័ណ្ឌខ្លឹមសារគតិយុត្តិ និងកាតព្វកិច្ចដែលបានគូស បញ្ជាក់ខាងលើ រដ្ឋភាគីត្រូវចាត់វិធានការដូចខាងក្រោម ដើម្បីធានាឲ្យ មានការអនុវត្តពេញលេញទៅលើមាត្រា១២ នៃអនុសញ្ញាអន្តរជាតិស្តីពី សិទ្ធិជនពិការះ

(ក) ទទួលស្គាល់ជនពិការជាមនុស្សនៅចំពោះមុខច្បាប់ដែលមាន បុគ្គលិកលក្ខណៈគតិយុត្តិ និងសមត្ថភាពខាងផ្នែកច្បាប់នៅក្នុងគ្រប់ ទិដ្ឋភាពនៃជីវិតដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។ ចំណុចនេះ ទាមទារឲ្យមានការលុបបំបាត់ចោលរបបធ្វើការសម្រេច ចិត្តជំនួស (និងយន្តការទាំងឡាយណាដែលបដិសេធសមត្ថភាពខាង ផ្នែកច្បាប់ដែលមានលក្ខណៈរើសអើងដោយចេតនា ឬជាធរមាន ទៅលើជនពិការ។ មានការផ្តល់អនុសាសន៍ថា រដ្ឋភាគីត្រូវបង្កើតភាសា ក្រោមអំណាចច្បាប់ ដែលការពារសិទ្ធិទទួលបានសមត្ថភាពខាង ផ្នែកច្បាប់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាសម្រាប់ទាំងអស់គ្នា

(ខ) បង្កើត ទទួលស្គាល់ និងផ្តល់ដល់ជនពិការនូវការទទួលបានការ គាំទ្រច្រើនបែបយ៉ាងនៅក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់ របស់ពួកគេ។ កិច្ចធានាការពារសម្រាប់ការគាំទ្រទាំងនេះ ត្រូវតែ ផ្អែកទៅលើគោលការណ៍នៃការគោរពសិទ្ធិ ឆន្ទៈ និងចំណង់ចំណូល ចិត្តរបស់ជនពិការ។ ការគាំទ្រទាំងនេះ ត្រូវបំពេញតាមលក្ខ័ណ្ឌ វិនិច្ឆ័យ ដែលមានចែងក្នុងកថាខណ្ឌ២៥ ខាងលើ ស្តីពីកាតព្វកិច្ច រដ្ឋភាគី ក្នុងការអនុវត្តតាមមាត្រា១២ កថាខណ្ឌ៣ នៃអនុសញ្ញា

(គ) ពិគ្រោះយោបល់ឲ្យបានជិតស្និទ្ធជាមួយជនពិការ និងឲ្យជនពិការចូលរួមយ៉ាងសកម្ម ដោយរាប់បញ្ចូលទាំងកុមារពិការផងតាមរយៈអង្គការតំណាងរបស់ពួកគេ នៅក្នុងការអភិវឌ្ឍន៍ និងអនុវត្តច្បាប់ គោលនយោបាយ និងដំណើរការធ្វើការសម្រេចចិត្តផ្សេងៗទៀត ដែលអនុវត្តឲ្យមានប្រសិទ្ធភាពនូវមាត្រា១២។

**៥១**. គណៈកម្មាធិការលើកទឹកចិត្តដល់រដ្ឋភាគីក្នុងការទទួលរ៉ាប់រង ឬបរិច្ចាគធនធានសម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ការអនុវត្តល្អបំផុតនានា ពាក់ព័ន្ធនឹងការគោរពសិទ្ធិទទួលបានការទទួលស្គាល់ ដោយស្មើភាពចំពោះសមត្ថភាពតាមផ្នែកច្បាប់របស់ជនពិការ និងការគាំទ្រក្នុងការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់នេះ។

**៥២**.រដ្ឋភាគីត្រូវបានលើកទឹកចិត្តឲ្យអភិវឌ្ឍយន្តការដ៏មានប្រសិទ្ធភាព ក្នុងការប្រយុទ្ធប្រឆាំងនឹងការធ្វើការសម្រេចចិត្តជំនួសជាផ្លូវការ និងក្រៅផ្លូវការ។ ដើម្បីសម្រេចបានគោលដៅនេះ គណៈកម្មាធិការជំរុញឲ្យរដ្ឋភាគីត្រូវធានាថា ជនពិការមានឱកាសក្នុងការជ្រើសរើសប្រកបដោយអត្ថន័យក្នុងជីវិតរបស់ពួកគេ និងមានឱកាសក្នុងការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់ពួកគេ ដើម្បីគាំទ្រដល់ការប្រើប្រាស់សមត្ថភាពខាងផ្នែកច្បាប់របស់ពួកគេ។ ក្នុងនោះរួមមានដូចជា៖ ឱកាសក្នុងការបង្កើតបណ្តាញសង្គម ឱកាសធ្វើការ និងរករបរចិញ្ចឹមជីវិតដោយស្មើភាពគ្នាជាមួយអ្នកដទៃ ជម្រើសច្រើនសម្រាប់ទីកន្លែងរស់នៅក្នុងសហគមន៍ និងការដាក់បញ្ចូលក្នុងវិស័យអប់រំនៅគ្រប់កម្រិត ប៉ុន្តែមិនដាក់កំរឹតចំពោះបញ្ហាទាំងអស់នេះទេ។